# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

ឆ្នាំទី ២៤ ខែមេសា លេខ ៤

ព.ស. ២៤៩៤ – គ.ស. ១៩៥២

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


| ផ្នែកសាសនា | បញ្ជីរឿង | ទំព័រ |
|---|---|---|
| ពន្លឺអាស៊ីទ្វីប (តមក) .......... | លោកភ័យ - ប៊ុក .......... | ២៤៣ |
| មលាមលកថា .............. | ព្រះមហា ទេព - សរ ...... | ២៤៧ |
| អត្តានុទិដ្ឋិ (តមក)............. | ឧកញ៉ា សំ - ស៊ុន ........ | ២៦០ |

**ផ្នែកអក្សរសាស្ត្រ**

| | | |
|---|---|---|
| ការបណ្ដុះនិស្ស័យ (តមក )........ | ព្រះមហាឧត្តមវិជ្ជា ប៊ុង - ប៉ម ... | ២៦៧ |
| រឿងសាមកុក (តមក )........... | ឧកញ៉ា ទួ - កន ......... | ២៧៦ |
| រឿងអារក្សថ្លែងរឿងម្ភៃប្រាំ (តមក ).... | លោក សាង - សាភ័ត ...... | ២៨២ |
| រឿងស្នេហាជាតិ (តមក)............ | លោក គង់ - លឹម ........ | ២៩០ |
| រឿងប៉ូលនឹងវីរ៉ស៊ីនី (តបក)......... | សាស្ត្រាចារ្យ ផេង - ជ្រីវ ..... | ២៩៨ |
| សំលៀកបំពាក់ខ្មែរ (តមក) ......... | ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ ..... | ៣០៤ |

**កំណត់នឹងប្រវត្តិការណ៍**

| | | |
|---|---|---|
| ជីវប្រវត្តិ ព្រះសុធម្មបញ្ញាត្ថេរ កែវ - ជួប | | |
| ចៅអធិការ វត្តកោះប្រាក់ (កំពង់ចាម) | ព្រះភិក្ខុ ម៉ី - សាន ....... | ៣១២ |



មួយឆ្នាំមាន ១២ សៀវភៅ — ជាថ្លៃជាវ ១៨៣រ.០០

# KAMBUJASURIYA

Revue religieuse et littéraire éditée par l'Institut Bouddhique.

---

## TABLE DES MATIÈRES

### PARTIE RELIGIEUSE


| | | Pages |
|---|---|---|
| La lumière de l'Asie (suite)..... | *M. Ray-Buc* .......... | 243 |
| Malâmalakathâ ............ | *VÉN. TEP-SAR* .......... | 247 |
| Attânudithi (suite)......... | *Oknha Sam-Sun* ........ | 260 |


### PARTIE LITTERAIRE


| | | |
|---|---|---|
| Education morale (suit )....... | *Vén.Pœung-Pam* ........ | 267 |
| Histoire de SAMKOK (suite) .... | *Oknha Nou-Kan* ........ | 276 |
| Les vingt cinq récits du Mauvais Génie (suite) ............. | *M. Sang-Savat* ........ | 282 |
| L'Amour de la Patrie (pièces de Théâtre) (suite)............. | *M. Kong-Lim* .......... | 290 |
| Paul & Virginie (suite)....... | *M. Phéng-Chrieu* ......... | 298 |
| Les vêtements Camdodgiens(suite) | *Commission des Mœurs et Coutumes* | 304 |


### NOTES ET CHRONIQUES


| | | |
|---|---|---|
| Biographie du vénérable Kèo-Chuop Chau-Adhikar de Vat Kos-Prak (Kg Cham) ............. | *VÉN.MI-SAN* .......... | 312 |


---


Prix d'abonnement annuel (12 numéros:) 18$00

# ពន្លឺអាស៊ីទ្វីប

## វគ្គទី ៨

**La Lumière de l'Asie**

*លោក ស៊ីរ-អេតវ៉ិន អារណូលត៍ តែង*

លោកវ៉ាយ-ប៊ុក ក្រមការ ប្រែរៀបរៀង

(តមក)

---

*គម្ពីរពោលពិត, តុបស៍អើយ ! ជីវភាពនៃមនុស្សនីមួយៗ គឺលទ្ធផលនៃការរស់នៅពីអតីតជាតិ, ការកំហុសពីអតីតជាតិ នាំមកនូវទុក្ខលំបាក, កុសលដែលបានបំពេញពីអតីតជាតិ នាំឲ្យកើតសោមនស្សចិត្ត ៗ អ្នកត្រូវតែច្រូតកាត់នូវពូជដែលអ្នកបានសាបព្រោះពីមុនមក ៗ អ្នកឃើញចម្ការនេះទេ ! ល្ងនេះពីដើមជាល្ង, ស្រូវសាលីនេះពីដើមជាស្រូវសាលី ៗ ចម្ងាត់នឹងស្រមោលគ្របនូវរឿងនេះទាំងអស់, ព្រោះហេតុដូចនេះបានជាកើតជោគវាសនារបស់មនុស្ស ៗ មនុស្សទើបនឹងច្រូតកាត់ល្ងនឹងស្រូវសាលី ដែលបានសាបព្រោះពីអតីតជាតិ, ហើយនឹងស្មៅអាក្រក់មានសភាពពុល ដែលធ្វើឲ្យមានជម្ងឺចំពោះមនុស្សនឹងទុក្ខចំពោះភពទាំងអស់ ៗ បើមនុស្សនោះ, ប្រព្រឹត្តករណីយកិច្ចដោយដកស្មៅអាក្រក់នោះចេញស្រឡះពីសន្តានហើយ ដាំពូជល្អបរិសុទ្ធស្អាតនៅកន្លែងដដែល គឺដីដែលមានជីជាតិល្អ មុខជាអ្នកត្រូវច្រូតនូវផលិតកម្ម*

ដំបរិបូណ៌មិនខាន ៗ បើអ្នកដែលរស់នៅ បានដឹងនូវហេតុដែលកើតទុក្ខ ហើយទទួលទុក្ខនោះដោយខន្តីព្យាយាមសងបំណុលចាស់ ដែលជំពាក់ដោយការកំហុសជាមុន ចំប្រព្រឹត្តនូវព្រហ្មវិហារធម៌សច្ចធម៌ តែកុំប្រព្រឹត្តនូវទារុណកម្មចំពោះអ្នកដទៃ, អ្នកនោះឈ្មោះថាបានលាងជម្រះមន្ទិលពីឈាមខ្លួន នូវពាក្យកុតករកុហកនៃអត្តទត្តភាព (egïsme) ឲ្យស្អាតពីសន្តានឈ្មោះថាបានទទួលទុក្ខ ដោយសេចក្តីរីករាយហើយមិនប្រកាន់ទោស ព្រមទាំងធ្វើចិត្តឲ្យល្អចំពោះសេចក្តីរំលោភនៃជនដទៃ; បើកល់ថ្ងៃមនុស្សនោះខំព្យាយាមធ្វើចិត្តទន់ភ្លន់ ប្រកបដោយសទ្ធិភាព, សុចរិតគួរជាទីពេញចិត្តស្មោះត្រង់ ហើយដកយកចេញគ្រប់កន្លែងទាំងអស់នូវតណ្ហាដែលបានចាក់ឫសភ្ជាប់ជ្រៅ ហូរឈាមសស្រាក់ទាល់តែការស្រឡាញ់ជីវភាពនោះរលត់រលាយអស់; បើអ្នកនោះប្រព្រឹត្តបែបនេះបាន, ដល់ធ្វើមរណកាលទៅ មុខជានឹងទៅកើតជាជាតិថ្មីគេហៅថាសំណុំអត្តាប្រកបដោយលទ្ធផលនៃជីវភាព ដែលគេបញ្ចប់នូវបញ្ជីបុណ្យបាប ប្រកបដោយទុក្ខផុតរលត់សង់រូបជ្រះស្រឡះហើយ, បញ្ជីបុណ្យប្រព្រឹត្តថ្មីឬយូរមកហើយ ស្ថិតនៅមានអានុភាពឲ្យផលល្អ អាក្រក់តាមហេតុក៏វិនាសសាបសូន្យ ។ មនុស្សបែបនេះ មិនត្រូវការនឹងជីវភាពៗដែលស្ថិតនៅពីមុនមកមានលំនាំផុតត្រឹមនេះ; អ្នកនោះបានបំពេញករណីយកិច្ចចំពោះជាតិសាសនាជាមនុស្សជាតិពេញលេញ ។ អ្នកនោះ

លែងទទួលទុក្ខទោស, បាបអកុសលមិនអាចធ្វើចិត្តឲ្យមន្ទិលសៅហ្មង, សេចក្តីទុក្ខដែលបានមកពីការសប្បាយក្នុងកាមិស និងការរងលំបាកនៅលើផែនដី លែងធ្វើឲ្យសន្តិភាព អ្នកនោះកករល្អក់ ហើយសេចក្តីស្លាប់នឹងកើតលែងវិលចុះឡើងចំពោះបុគ្គលបែបនេះជាដាច់ខាត ។ អ្នកនោះចូលទៅកាន់ព្រះនិព្វាន ។ អ្នកនោះរួមស្និទ្ធជិតតែមួយឯកឯងក្នុងជីវភាព តែអ្នកនោះលែងរស់នៅក្នុងលោក ; អ្នកនោះបានក្រេបនូវអនាមិសសុខ ដោយហេតុអ្នកនោះលែងយោនយកកំណើតទៀត, ឧម-មុនី បទ្មេ, ឧម[១] ដំណក់ទឹកសន្សើមស្រក់ចូលទៅបាត់ក្នុងមហាសាគរ ។

នេះជាលទ្ធិកម៌; ចូរអ្នកចំហាត់ស្វាធ្យាយឲ្យច្បាស់ ។ លុះត្រាតែលំអងនៃបាបនោះរលាយបាត់សាបសូន្យ, លុះត្រាតែជីវិតផុតរលត់ដូចជាអណ្តាតភ្លើងដែលថមថយកំឡាំងដោយគ្មានប្រេង, ទើបសេចក្តីស្លាប់នោះរលត់រលាយទៅជាមួយនឹងជីវិតនោះជាអវសាន ។ កុំឲ្យពោលថា: "ខ្ញុំស្ថិតនៅទីនេះក្នុងបច្ចុប្បន្ន, ខ្ញុំស្ថិតនៅទីនោះពីអតីតកាល" ឬ "ខ្ញុំស្ថិតនៅទីនេះក្នុងអនាគតកាល" ។ កុំគិតថា អ្នកចេញពីផ្ទះសាច់មួយទៅនៅផ្ទះសាច់មួយទៀតដូចជាអ្នកដំណើរចាំច្បាស់លាស់ ឬភ្លេចថាបានសំណាក់នៅទីនោះដោយស្រួលបួល ឬដោយលំបាក ។ ពីអតីត, ឥឡូវ

---

១ ឧម, រតនៈ ក្នុងបុប្ផាបទុម ធម៌ដែលពួកពុទ្ធមាមកជនខាងទីបេត៍សូត្រ ។ ព្រះពុទ្ធរូបគេតែងប្រតិស្ឋានព្រះហស្តកាន់ផ្កាឈូកដែលមានរតនវត្ថុនៅក្នុងនោះ ។

នោះស្ថិតនៅជាអធិបតេយ្យលើភពទាំងអស់មុនទឹងក្មេងចេះគល្ប ៗ ឱបងប្អូនអើយ! តើអ្វីជាឧបសគ្គ? គឺងងឹតដែលផ្សាយចេញពីអវិជ្ជានាំឲ្យអ្នកទាំងអស់គ្នាវង្វេង, យកសភាពភាន់ច្រឡំថាជាសភាពមែនពិត ហើយនាំឲ្យកើតនូវតណ្ហាប្រាថ្នានូវសភាពភាន់ច្រឡំនោះៗ ដល់សេចក្តីប្រាថ្នានោះមកដល់ពេលជាអវសាន, ត្រូវការបូកប្រមូលនូវជីវភាពវិលត្រឡប់ចូលទៅក្នុងចក្រវាឡវិញ ; ជីវភាពនោះបានសង់នូវគេហដ្ឋានរបស់ខ្លួនដូចជាដង្កូវនាងចូលទៅស្ថិតនៅក្នុងសំបុក ៗ ហើយបានចូលទៅរួមនាមនិងរូបតែមួយឯកឯងមានមុខការផ្សេង ៗ ដូចជាពងពស់ក្នុងខណៈដែលមេក្រាប, ពស់នោះអាចផ្សាំនូវស្រកានិងចង្កូមឲ្យបានស្រួល, ដូចជាពូជដើមត្រែង ហិចហើរទៅលើថ្មកំ ថ្មដានិងខ្សាច់ ទាល់តែទៅដល់បឹងជ្រះធ្លាក់ចុះចំរើនដុះដាលឡើងជាលំដាប់ ៗ ដូចគ្នានឹងជីវភាពនោះវិលត្រឡប់មករកសុខ ឬទុក្ខវិញ ៗ កាលណាសេចក្តីស្លាប់នាំមកនូវផលអាក្រក់ចំពោះពេជ្ឈឃាត, បាបអកុសលដែលមន្ទិលប៉ុន្មាន ក៏ត្រាច់រង្គាត់ទៅក្នុងសមុទ្រសង្សារដោយអំណាចវាយោដែលប្រកបដោយអដ្ឋជាកាសងងឹតចុះអ័ព្ទហើយមានសភាពពុលនោះផង ៗ តែបើមនុស្សនោះល្អសុចរិតទទួលមរណភាព, មានវាយោបក់ត្រជាក់ស្រួល ; ពិភពលោកមានសភាពរីកស្រស់ស្រាយ, ដូចជាទន្លេនៅពេលខ្សាច់រហោស្ថានហូរបាត់ទៅក្នុងខ្សាច់មួយរំពេចហើយទើបចេញហូរជាថ្មីភ្លឺចាំងបរិសុទ្ធស្អាតដូច្នោះ ៗ (មានត)

មលាមលកថា

# ព្រះមហាទេព - សរ វត្តឧណ្ណាលោម ក្រុងភ្នំពេញ

ទេសនាដាក់វិទ្យុឃោសនសព្ទ នៃប្រទេសកម្ពុជា កាលពីថ្ងៃ ១៥ កើត ខែភទ្របទ
ឆ្នាំជូតសំរឹទ្ធិស័ក ព. ស. ២៤៩១ (១៨ – ៩ – ៤៨)

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

វេលានេះអាត្មាភាពនឹងសំដែងអំពីមលាមលកថា ផ្សាយតាមវិទ្យុឃោសនសព្ទ ចែកជូនសប្បុរសទាំងឡាយ, តែមុននឹងសំដែងនូវ "មលាមលកថា" នេះ សូមរាប់រៀបជម្រាលសេចក្ដីខាងដើមបន្តិច ដើម្បីឲ្យសមរម្យនឹងពុទ្ធភាសិតដែលត្រូវលើកមកសំដែង ។

អស់លោក-អ្នកទាំងឡាយសុទ្ធតែជាខេមរជាតិ គេដឹងសព្វប្រទេសថាជាអ្នកកាន់ព្រះពុទ្ធសាសនា គួរតែឲ្យមានសេចក្ដីរីករាយក្នុងចិត្តថាមានភ័ព្វព្រេងសំណាងយ៉ាងខ្ពស់ ត្រង់ដែលបានមកជួបប្រទះនឹងព្រះពុទ្ធសាសនា ព្រោះព្រះពុទ្ធសាសនាជាគុណជាតិមានគោលចារិកត្រឹមត្រូវល្អ និងជាគុណជាតិដ៏ឧត្តម អាចធ្វើអ្នកប្រតិបត្តិតាមឲ្យបានចំរើនដោយការប្រះដឹងនឹងសេចក្ដីថ្លៃថ្លា ។ តែអ្នកដែលមានឈ្មោះថា អ្នកកាន់ព្រះពុទ្ធសាសនាចំពូកខ្លះ ដែលពុំបានសិក្សាឲ្យស្គាល់ជាក់ នូវរសជាតិព្រះពុទ្ធសាសនា ក៏នៅមានគំនិតប្រាជ្ញាឆេងឆោងដោយសេចក្ដីជឿងល់ ។

ដូចជាអ្នកខ្លះ ដែលបានឃើញអ្នកកាន់ព្រះពុទ្ធសាសនាខ្លះ ដែលពុំសូវចេះដឹងជាអ្នកទាបថោក ជាអ្នកក្រីក្រលំបាក ក៏ចូលចិត្តថាព្រះពុទ្ធ-សាសនាទាបថោកណាស់, ធ្វើអ្នកប្រតិបត្តិតាមឲ្យល្ងង់ ឲ្យទាបថោកឲ្យក្រីក្រលំបាក ម្ល៉ោះហើយក៏មិនយកចិត្តទុកដាក់នឹងព្រះពុទ្ធសាសនាឲ្យជាការមាំមួនឡើយ នេះមកពីអ្នកនោះឯងមិនបានសិក្សាមិនបានពិនិត្យឲ្យឃើញតាមការពិតមែន ។

មានជនខ្លះទៀត បានចូលមកសិក្សាចំណេះវិជ្ជាខាងផ្លូវព្រះពុទ្ធ-សាសនាមានចំណេះអក្សរជាដើម នៅទីវត្តអារាមដែលជាទីបណ្តុះនៃពូជចំណេះខាងព្រះពុទ្ធសាសនាតាំងពីក្មេងមក អ្នកខ្លះបានទាំងបួសថែមទៀតតែមិនប្រឹងប្រែងរៀនសូត្រឲ្យចេះដឹងប្រាកដមែនទែន លុះដល់វេលាដែលចេញពីវត្តអារាមទៅ បានទៅសិក្សាចំណេះឯទៀតក្រៅពីលទ្ធិព្រះពុទ្ធសាសនា ក៏ត្រឡប់ឃើញថាព្រះពុទ្ធសាសនាមិនរៀបរយ មិនថ្លៃថ្នូដូចជាចំណេះវិជ្ជាឯទៀត ម្ល៉ោះហើយក៏នាំគ្នានិយាយបន្ទុះបន្ទាប់ចំណេះដែលចេះពីវត្តអារាមទៅ គឺថាបើឃើញចំណេះណាមួយដែលមិនប្រាកដ ឬឃើញអក្សរដែលអ្នកណាមួយសរសេរមិនល្អ ក៏នាំគ្នានិយាយថាចំណេះវត្ត អក្សរវត្តប្រើការមិនកើត ដូចជាទីវត្តរមែងធ្វើមនុស្សអ្នករៀនមិនប្រាកដ ត្រង់ខ្លួនឯងដែលខ្ជិលរៀនសូត្រមិនគិតឃើញដល់ នេះមកពីគំនិតឃើញខុសព្រោះលុះក្នុងអំណាចនៃសេចក្តីកាន់ច្រឡំ ។

អស់លោក អ្នកទាំងឡាយ ប្រយ័ត្នកុំឲ្យភាន់ច្រឡំគំនិតដូចមនុស្សចំពួកខ្លះ ដែលគិតឃើញខុសដូចខាងលើនេះឡើយ ត្រូវចូលចិត្តឲ្យមាំថា ព្រះពុទ្ធសាសនានេះ ជាច្បាប់ប្រដៅមនុស្សដែលជឿប្រតិបត្តិតាម ឲ្យមានប្រាជ្ញា, ឲ្យមានចំណេះវិជ្ជាផ្លូវលោកព្រមទាំងផ្លូវធម៌ ឲ្យមានរបៀបរៀបរយល្អ, ឲ្យបានបរិសុទ្ធផុតចាកមន្ទិលគ្រប់យ៉ាង ។

សាសង: ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ដែលមានមកក្នុងផ្លូវសាសនាមានច្រើនជាអនេក សុទ្ធតែជាពាក្យប្រកបដោយប្រយោជន៍ទាំងអស់, ជាពាក្យតឿនក្រើនរំឭកមានហេតុផលល្អ យ៉ាងសំខាន់ ឲ្យស្គាល់ផ្លូវចំរើននឹងវិនាស សមដូចពុទ្ធភាសិតមួយក្នុងមាននៅ ក្នុងគម្ពីរធម្មបទខុទ្ទកនិកាយពោលទុកមកថា:

អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា
មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ ។

ប្រែសេចក្តីថា: "មន្តសិល្បសាស្ត្រទាំងឡាយ មានការមិនស្វាធ្យាយជាមន្ទិល, គេហស្ថាន (ប្រទេសជាតិមាតុភូមិ) មានការមិនក្រោកក្រើនជាមន្ទិល, ការខ្ជិលច្រអូសជាមន្ទិលនៃពណ៌សម្បុរកាយ, សេចក្តីធ្វេសប្រហែសជាមន្ទិលនៃបុគ្គលអ្នករក្សា" ។

ក្នុងផ្ទៃគាថានេះ អធិប្បាយចែកទៅជា ៤ មាតិកា នឹងសូមដកស្រង់តាមលំដាប់មាតិកាយកមកអធិប្បាយ ដូចសេចក្តីដែលជាប់ទាក់ទងគ្នាតទៅនេះ

ទី ១ — អសជ្ឈាយមលា មន្តា មន្តវិជ្ជាសាស្ត្រមានការមិនស្វាធ្យាយជាមន្ទិល ។ ក៏ពាក្យថា មន្តសព្វនេះ បើតាមលោកវោហារដែលធ្លាប់នាំគ្នាចូលចិត្តមកអស់កាលជាយូរ សំដៅយកមន្តអាគមអូមអាមសម្រាប់ស្ដោះបណ្ដេញខ្មោចអាបព្រាយ ទីឯមន្តអាគមសម្រាប់សូត្រការពារកាប់ចាក់មិនមុតដុតមិនឆេះតែម្យ៉ាងប៉ុណ្ណោះ, តែបើតាមសេចក្ដីពិតដែលមានមកក្នុងគម្ពីរផ្លូវសាសនា គឺសំដៅយកមន្តវិជ្ជាផ្លូវព្រះពុទ្ធ-សាសនា ទីឯផ្លូវលោកទាំងស្រុង, ដែលជាមន្តវិជ្ជាសម្រាប់ធ្វើខ្លួនឲ្យរួចពីឋានៈទន់ទាបឡើងទៅកាន់ឋានៈខ្ពង់ខ្ពស់, ទីឯមន្តវិជ្ជាសម្រាប់ប្រើផ្លូវការរកស៊ីចិញ្ចឹមជីវិត ប្រាសចាកទោសគ្រប់យ៉ាង, វិជ្ជាអស់ទាំងនេះខេមរជនទាំងឡាយ ត្រូវតែសិក្សាសូត្ររៀនឲ្យបានចេះចាំមាំមួនគ្រប់ៗគ្នាឡើង ព្រោះថាផ្លូវសាសនា ទីឯផ្លូវលោកទាំងពីរនេះ ត្រូវប្រស័យជាប់ទាក់ទងទៅវិញទៅមក បើមានតែណាមួយក៏មិនអាចប្រព្រឹត្តទៅបាន, តួយ៉ាងដូចជាគ្រឿងចក្រទាំងឡាយ មានរថយន្តជាដើម ដែលអាចបើកបរទៅបាន ត្រូវអាស្រ័យគ្រឿងទព្វសម្ភារៈគ្រប់យ៉ាង បើមានតែកង់ហើយខ្វះតួរថ ឬក៏មានតែរថហើយខ្វះគ្រឿងម៉ាស៊ីន ក៏មិនអាចប្រព្រឹត្តទៅបាន ។

លោកអ្នកខេមរៈទាំងឡាយ ! មន្តវិជ្ជាសាស្ត្រទាំងនេះដែលបានរៀនចេះចាំមក ហើយបើមិនសប្ដាហ៍ស្វាធ្យាយសូត្រទន្ទេញ មើល

ឲ្យញឹកញយទេ រមែងភ្លេចភ្លាំងបាត់បង់ទៅវិញពុំខាន, ត្រឡប់ទៅជារបស់ឥតប្រយោជន៍ ប្រើការមិនកើត, បើទុកជាមាននៅចាំខ្លះក៏ពុំប្រាកដ. បែបស្រពិចស្រពិលព្រិលៗព្រាវៗ ស្ទាក់ស្ទើរក្នុងចិត្តរកប្រាកដកន្លែងណាមិនបាន តែងត្រឡប់ឲ្យទោសដល់ខ្លួនវិញ សមដូចបុរាណកាសិតពោលទុកមកថា:

អនភ្យាសេ វិឞំ វិទ្យា  អជិណ្ណេ ភោជនំ វិឞំ
វិឞំ សភា ទរិទ្រស្យ  វ្ឫទ្ធស្យ តរុណី វិឞំ ។

" មន្តសិល្បសាស្ត្រទាំងឡាយ ដែលរៀនចាំមិនប្រាកដបែបស្ទាក់ស្ទើរ ប្រើការមិនកើត ទុកដូចជាគ្រឿងពិស ភោជនដែលបុគ្គលបរិភោគទៅហើយមិនរលាយក៏ទុកដូចជាគ្រឿងពិសដែរ, ទីប្រជុំជាគ្រឿងពិសដល់មនុស្សដែលកំសត់ទីទ័លក្រ, មនុស្សចាស់យកប្រពន្ធក្រមុំ ទុកស្មើនឹងគ្រឿងពិសយ៉ាងចំហុតមួយដែរ " ។

ព្រោះបណ្ដាមន្តវិទ្យាសាស្ត្រទាំងអស់ក្នុងលោក តែងមានការឧស្សាហ៍មើល, ទន្ទេញ-ស្វាធ្យាយ ឲ្យញឹកញាប់ជាប្រមុខ, បើរៀនចេះមកហើយ បណ្ដែតបណ្ដោយលះបង់ចោលរមែងលែងមានការប្រាកដក្នុងចិត្តពុំខាន ។ ដោយហោចទៅ សូម្បីតែលះបង់ចោលត្រឹមតែ ៥-៦ ថ្ងៃប៉ុណ្ណោះ ក៏គង់មានការភាន់ភាំងផើងផោង ចំណង់បើបោះបង់ចោលការ

សិក្សាអស់ខែ - ឆ្នាំ សម្បីតែរំផ្លាក់ទេចក់ទី រំកាច់រំកោចអ្វីមួយក៏គ្មានជក់នៅក្នុងខ្លួនដែរ, សមដូចជាច្បាប់លោកនីតិពោលទុកមកថា :

បញ្ជរត្យា សុគន្ធញា សត្ថរត្យា ធនុគ្គហា
ឯកមាសា សុភរិយា អឌ្ឍមាសា សិស្សា មលា

" រប៉ាំបង់លេងលង់ ៥ ថ្ងៃ ជាមន្ទិលគឺដៃខុសលំអាន
នាយខ្មាន់ធ្នូបង់បាញ់កន្លងបាន ៧ ថ្ងៃក៏មានមន្ទិលភ្លាត់ ។
ប្រពន្ធបង់ប្ដីលង់ ១ ខែ ជាមន្ទិលគឺប្រែចិត្តប្រតិព័ទ្ធ
សិស្សបង់ការសិក្សាក្នុងវត្ត កន្លះខែក៏ភ្លាត់ការសិក្សា " ។

ចំក្នុងសេចក្ដីឲ្យឃើញថា : អ្នកណាមួយតែលះបង់ការសិក្សាចោលហើយឈ្មោះថា ជាអ្នកល្ងង់មិនចេះមិនដឹង កាលបើល្ងង់មិនចេះមិនដឹងហើយទុកស្មើគ្នានឹងសត្វគោ សមគ្នានឹងបុរាណកាសិត ១ កន្លែងក្នុងគម្ពីរហិតោបទេសថា :

អាហារនិទ្រា ភយំ ច មេថុនំ សាមាន្យមេតត្បសុភិនរាណាម៑
ធម៌ោហិតេឞាមធិកោវិឝេឞោ ធម៌េណហិនាះបឝុភិះសមានាះ

"មនុស្សនឹងសត្វគោ មានការបរិភោគអាហារ នឹងដេកនឹងភ័យនឹងសេពមេថុនដូចគ្នា តែមនុស្សមានចំណេះវិជ្ជាសម្រាប់ធ្វើឲ្យប្លែកអំពីគោ មនុស្សណាឥតមានចំណេះវិជ្ជា មនុស្សនោះឈ្មោះថាស្មើគ្នានឹងសត្វគោ " ។

ឯទោសនៃសេចក្ដីល្ងង់នេះសឹងឃើញច្បាស់ក្នុងបច្ចុប្បន្ននេះដូច្នេះ

១) បើល្ងង់ក្នុងវិធីអក្សរគឺមិនចេះសរសេរ-មើល នឹងនាំឲ្យខាតបង់នូវប្រយោជន៍ដូច្នេះគឺៈ មិនអាចមើលសៀវភៅដែលជាច្បាប់ប្រដៅល្អក្នុងព្រះពុទ្ធសាសនាឬក្រៅពីពុទ្ធសាសនា, មិនអាចសរសេរសំបុត្រដោយខ្លួនឯង ផ្ញើដំណឹងដល់ញាតិមិត្តដែលខ្លួនត្រូវការ, សេចក្ដីកំបាំងឬការក្រដែលញាតិមិត្តឲ្យដំណឹងមកចំពោះខ្លួន នឹងមិនសម្រេចប្រយោជន៍ ។

២) អ្នកដែលល្ងង់ បើអាស្រ័យនៅជ្រកកោនក្នុងសំណាក់អ្នកធំ ចេះគោរពប្រតិបត្តិឲ្យអ្នកធំស្រឡាញ់មេត្តាដូចម្ដេចក្ដី អ្នកធំនោះក៏មិនអាចលើកដំកើងអ្នកនោះឲ្យមានកេរ្តិ៍ឈ្មោះយសស័ក្តិបានឡើយ ។

៣) មនុស្សល្ងង់ ទោះមានយសស័ក្ដិដោយព្រេងសំណាងជួយឧបត្ថម្ភ បើចំរើនគ្រាន់បើបានតែក្នុងទីឯទៀត តែដល់ចូលកាន់ទីប្រជុំនឹងត្រឡប់ទៅជាមនុស្សឥតរាសីឥតមានដម្លៃទៅវិញ ព្រោះហានិយាយឡើងមិនត្រូវតាមច្បាប់ ។

៤) មនុស្សល្ងង់ ជាមនុស្សខ្វះមិត្តសំឡាញ់ ព្រោះគេមិនត្រូវការយកខ្លួនធ្វើជាមិត្តសំឡាញ់ឡើយ ។ បើទុកជាមានមិត្តសំឡាញ់ក៏ច្រើនបានតែមិត្តសំឡាញ់ដែលជាមនុស្សល្ងង់ជាងខ្លួន ។

៥) មនុស្សល្ងង់ បើរកស៊ីតាមធម្មតា ក៏មិនអាចនឹងធ្វើឲ្យចំរើនដូចមនុស្សដែលមានប្រាជ្ញាចេះដឹងឡើយ បើទុកជាធ្វើទៅត្រូវលើទំនង ឬកាលដែលគួរធ្វើ ក៏មិនរួចពីសេចក្ដីលំបាក ។

៦) មនុស្សល្ងង់ មិនដែលបានសេចក្ដីសរសើរ អំពីសំណាក់អ្នកប្រាជ្ញណាមួយដល់ម្ដងឡើយ បើបានសរសើរខ្លះ តែអំពីសំណាក់បុគ្គលដែលល្ងង់ជាងខ្លួន ។

ទោសនៃសេចក្ដីល្ងង់នេះ មិនមែនមានតែក្នុងបច្ចុប្បន្ននេះទេ នឹងមានទៅក្នុងលោកឯមុខទៀតជាអនេក តែមិនបានអធិប្បាយឲ្យសព្វគ្រប់ក្នុងទីនេះ ។

២– អគ្ឃិធមលា យរា គេហដ្ឋាន (ប្រទេសជាតិមាតុភូមិ) មានការបណ្ដែតបណ្ដោយមិនជួសជុលទល់ទ្រ ជាមន្ទិល ។

ក៏ពាក្យ "ឃរៈ" សព្ទនេះ សំដៅយកទីសេនាសនៈសម្រាប់ទីពឹងសំណាក់ស្នាក់អាស្រ័យនៃគ្រហស្ថនិងបព្វជិតទូទៅក្នុងលោក គឺផ្ទះសំបែងកុដិសាលា ប្រាង្គចេតិយជាដើម, កាលបើមន្ទិលគឺការចាស់ជុនជាបទ្រុឌទ្រោមហើយ, មិនឧស្សាហ៍មើលថែទាំជួសជុលឡើងវិញទេ រមែងបាក់បែកធ្លុះធ្លាយរេចរឹលបន្តិចម្ដងៗ ដរាបទាល់តែរកកន្លែងសំណាក់បាក់ប៉ុនអាស្រ័យតទៅទៀតពុំបាន, នឹងបណ្ដាលឲ្យជួបប្រទះ តែសេចក្ដីទុក្ខវេទនាចំពោះខ្លួនឯងតែម្យ៉ាង, មិនត្រឹមតែទីសេនាសនៈ សម្រាប់នៅពឹងពាក់ផ្ទាល់ខ្លួនប៉ុណ្ណោះទេ សូម្បីតែប្រទេសជាតិមួយដែលជាប្រយោជន៍ធំទូទៅគ្រប់មនុស្សទាំងអស់, កាលបើបណ្ដែតបណ្ដោយមិនមើលការថែទាំចាត់ការឲ្យបានមានរបៀបរៀបរយត្រឹមត្រូវល្អទេ ឬ ក៏បណ្ដោយឲ្យពួក

បច្ចាមិត្តចូលមកលុកលុយរុករានតាមអំពើចិត្តបានហើយ, ប្រទេសនោះឯងប្រាកដធ្លាក់ទៅកាន់ការអាប់ឱនដុនដាបដោយឆាប់រហ័សពុំខាន, នេះក៏ចាត់ជាមន្ទិលមួយដែរ ។

៣– មលំ វណ្ណស្ស កោសជ្ជំ សេចក្តីខ្ជិលច្រអូសជាមន្ទិលនៃពណ៌ ។ អធិប្បាយថា: តួរូបរាងកាយរបស់មនុស្សប្រុស ស្រីទាំងស្រុងក្តី, ទោះវត្ថុសម្រាប់ប្រើប្រាស់ទូទៅទាំងអស់ក្តី, បើខ្ជិលច្រអូសមិនឧស្សាហ៍បោកគក់លាងដុសដូតខាត់សំអាតឲ្យញឹកញយទេ នឹងជាហេតុនាំបណ្តាលឲ្យរូបកាយរបស់យើងដែលអាស្រ័យនូវគ្រឿងមិនស្អាតមានរោគផ្សេងៗ ។ កាលបើរូបកាយមានរោគហើយ ចិត្តដែលអាស្រ័យខាងក្នុងរូបកាយ ធ្វើម្តេចនឹងប្រព្រឹត្តទៅបានដោយស្រួល កាលបើចិត្តប្រព្រឹត្តទៅមិនស្រួលហើយ គំនិតប្រាជ្ញាដែលនៅអាស្រ័យនឹងចិត្ត ធ្វើម្តេចនឹងដុះដាលភ្លឺស្វាងឡើងបាន កាលបើគំនិតប្រាជ្ញាមិនចំរើនភ្លឺស្វាងហើយ ប្រយោជន៍ដែលយើងត្រូវការចង់បានក្នុងបច្ចុប្បន្ននេះ នឹងលោកខាងមុខ ធ្វើម្តេចនឹងសម្រេចប្រយោជន៍បាន ។

កាលបើយ៉ាងនេះគួរតែចូលចិត្តថា បណ្តារោគទាំងអស់ សុទ្ធតែជាគួសត្រូវប្តូជាមេចោរជាអ្នកបំផ្លាញ នូវប្រយោជន៍នៃអស់យើងពល់គ្នា ព្រោះសេចក្តីពិតថា អ្នកណាមួយទោះបីមានបុណ្យស័ក្តិក្តី មានទ្រព្យសម្បត្តិច្រើនក្តី, មានប្រាជ្ញាច្រើនក្តី, មានកំឡាំងច្រើនក្តី, កាលបើ

រោគចូលមកអាស្រ័យនៅក្នុងរូបកាយបានហើយ បុណ្យស័ក្តិជាដើមនោះ ក៏ត្រឡប់ទៅជាឥតមានអានុភាព, ប្រការមិនកើតទាំងអស់ ព្រោះតាលបាញអំណាចនៃរោគដែលចូលមកលុកលុយក្នុងរូបកាយ ។

មិនតែប៉ុណ្ណោះសោត ការដែលស្លោកគ្រោកមិនខ្សោហ៍សំអាតគ្រឿងប្រើប្រាស់ ឲ្យបានស្អាតបាតនេះជាហេតុនាំឲ្យអប្បសិរីសួស្តីគ្រប់យ៉ាង មិនសូវមានការគោរព រាប់អានអំពីសំណាក់បុគ្គលដទៃ សមដូចបុរាណភាសិតថា :-

វិត្ថេន វិភូសា ភិហា វិឡយា វិនយេន ច
វិក្កា៍ន បញ្ច ភិនោ៎ ននោ នាយាតិ គោរវំ ។

"ជនណាប្រាសចាកគោលគុណធម៌ ទាំង៥ប្រការស្រោបលោក គឺមួយស្លៀកពាក់ស្អាតមានជោគ ពីរមិនស្លោកគ្រោកស្អិតស្អាង
កាយ" ។

បីសំដីផ្អែមល្ហែមពិសេស បួនវិជ្ជាចេះដឹងស្រួសសាយ
ប្រាំវិន័យក្រិត្យក្រមទាំងឡាយ ជននោះមិនងាយគេគោរព ។

ហេតុនេះគួរតែយើងខ្សោហ៍សំអាតទីលំនៅជាដើម ដើម្បីទីងការពារបិទផ្លូវកុំឲ្យរោគកើតឡើងបាន; ពិតមែនតែមានពុទ្ធភាសិតមួយកន្លែងសំដែងថា រូបំ រោគនិឌ្ឌំ "រូបជាទីកប់នៃរោគ ឬជាទីអាស្រ័យនៅនៃរោគ", ដែលព្រះអង្គសំដែងដូច្នេះ ចំពោះត្រង់កន្លែងដែលរោគចូលទៅ

អាស្រ័យនៅគឺរូបកាយ បើឥតរូបកាយក៏ឥតមានរោគ តែមានរូបកាយហើយក៏ឈ្មោះថាមានរោគ ។ ឯរោគសមុដ្ឋាន គឺហេតុដែលនាំបណ្ដាលឲ្យរោគកើតឡើងនោះ ព្រះអង្គមិនបានសំដែងចំពោះត្រង់ពាក្យថា "រូបំ រោគនិឍ្ឌំ" នេះទេ រោគសមុដ្ឋាននោះ ព្រះអង្គមានសំដែងទុកក្នុងសូត្រឯទៀតដោយច្រើន មានគិរិមានន្ទសូត្រជាដើម ។

ម្យ៉ាងទៀត, ការសំអាតនេះ មិនមែនមានតែក្នុងដំរាបបច្ចុប្បន្ននេះឡើយ ច្បាប់ក្នុងព្រះពុទ្ធសាសនាក៏មានសំដែងដោយច្រើន ។ តួយ៉ាងដូចក្នុងគម្ពីរវិសុទ្ធិមគ្គ ត្រង់សមាធិនិទ្ទេសជាដើម មានសំដែងអំពីអប្បនាកោសល្ល ១០ យ៉ាង, ត្រង់អប្បនាកោសល្លទី ១ ឈ្មោះ វត្ថុវិសទកិរិយា សេចក្ដីថា ធ្វើវត្ថុខាងក្នុងនិងខាងក្រៅឲ្យស្អាត ។ ធ្វើវត្ថុខាងក្នុងឲ្យស្អាត គឺធ្វើរូបកាយឲ្យស្អាត មានកាត់ក្រចក កោរសក់និងដំរះដុសលាងខ្លួនមិនឲ្យមានញើសក្អែលជាដើម ។ ធ្វើវត្ថុខាងក្រៅឲ្យស្អាត គឺសំអាតគ្រឿងស្លៀកពាក់ និងទីដេកទីអង្គុយជាដើមឲ្យបានស្អាតបាត ។ កាលវត្ថុខាងក្នុងនិងខាងក្រៅស្អាតល្អហើយ ។ ទៅអង្គុយចំរើនព្រះកម្មដ្ឋាន ចិត្តនិងចេតសិកក៏ប្រព្រឹត្តទៅដោយស្រួល កាលបើចិត្តនិងចេតសិកស្រួលហើយ ញាណគឺប្រាជ្ញាដែលអាស្រ័យនៅនឹងចិត្ត ក៏ភ្លឺស្វាងរុងរឿងល្អ, ឧបមាដូចជាប្រទីបគឺចង្កៀងគោម កាលបើតួប្រទីបស្អាត ប្រេងក៏ល្អ ប្រឆេះក៏ល្អ លំដូងក៏ស្អាតល្អ ពន្លឺប្រទីបនោះក៏ភ្លឺរុងរឿងឡើងបាន ។

កាលបើវត្តមានក្នុងទីនោះក្រៅមិនស្អាតល្អហើយ ញាណ គឺប្រាជ្ញាមិនអាចភ្លឺរុងរឿងបាន ។

សូមអស់លោក-អ្នកទាំងឡាយ ខ្សោយសំអាតជួបសេចក្តីខាងលើនេះ នឹងបានត្រូវតាមដំណក្នុងបច្ចុប្បន្ននេះផង ត្រូវតាមច្បាប់ព្រះពុទ្ធ-សាសនាផង ព្រមទាំងបានប្រយោជន៍ផ្សេងៗ ផង មានកំចាត់បង់នូវរោគចេញអំពីកាយជាដើម កាលបើរាងកាយឥតមានរោគហើយ ឈ្មោះថាបានលាភដ៏ឧត្តមសមនឹងពុទ្ធភាសិតថា " អារោគ្យបរមា លាភា " មានលាភអ្វីមិនឧត្តមស្មើនឹងគ្មានរោគ" ។ សេចក្តីថា: អ្នកឥតរោគអាចនឹងទទួលនូវលាភគ្រប់យ៉ាងបាន ឯអ្នកដែលមានរោគ សូម្បីលាភឯណាមួយកើតឡើងក៏មិនអាចទទួលយកបាន បើទុកជាបានក៏មិនអាចសោយសេចក្តីសុខព្រោះលាភនោះបានឡើយ ព្រោះខ្លួនជាអ្នកមានរោគ រកសេចក្តីសុខគ្មាន ។

៤— បមាទោ រក្ខតោ មលំ បមាទធម៌ជាមន្ទិលនៃបុគ្គលអ្នករក្សា ។ សេចក្តីថា: បមាទ: សព្ទនេះ ប្រែថាធ្វេសប្រហែស, បណ្តែតបណ្តោយកិច្ចការផ្សេងៗគ្រប់យ៉ាង, បមាទធម៌នេះ ព្រះសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សំដែងថាជាមេអកុសលគ្រប់យ៉ាង; ព្រោះថាបណ្តាធម៌ជាអកុសលទាំងឡាយ ដែលអាចផុះផាលព្រួតលាស់ឡើងបានព្រោះមានបមាទធម៌ជាប្រមុខ ឬក៏មានបមាទធម៌ជាប់នៅក្នុងសន្តានចិត្តពីមុនមកស្រាប់, ខ្វះបមា

ដូចជាមេដំកូលប្រាសាទជាទីរួបរួមនៃគ្រឿងទព្វសម្ភារៈ គ្រប់យ៉ាងមានផ្តាំងផ្តានជាដើម ៗ បមាទធម៌នេះកាលបើចូលមកនៅក្នុងសន្តានជនណាមួយហើយ, ជននោះឯងប្រាកដជាភ្លេចនឹកដល់សេចក្តីល្អ-ចំរើនគ្រប់យ៉ាង តែងញុំាងចិត្តរបស់ខ្លួនឲ្យឈ្ងប់ងប់ក្នុងសេចក្តីអាក្រក់តែម្យ៉ាង, រមែងធ្វើអត្តភាពរបស់ខ្លួនឲ្យធ្លាក់ទៅកាន់សេចក្តីទុក្ខអស់កាលជាអង្វែង ៗ

មិនតែប៉ុណ្ណោះឡើយ សូម្បីតែប្រទេសនិមួយៗ ដែលធ្លាក់ទៅកាន់សេចក្តីអាប់ឱនធុនជាបថោកទាប ក៏ដោយសារស្នាដៃបមាទធម៌នេះដែរ ៗ

តែមានជនខ្លះចូលចិត្តស៊ប់ថា: ការចំរើននឹងវិនាស, មាននឹងក្រ ស្រេចតែនឹងសំណាងវាសនារបស់ខ្លួនតែម្យ៉ាង ៗ សូមអស់លោក-អ្នកទាំងឡាយកុំចូលចិត្តស៊ប់យ៉ាងនេះឡើយ, ត្រូវចូលចិត្តថា ការចំរើននឹងវិនាស, មាននឹងក្រ ស្រេចតែខំប្រឹងប្រែងព្យាយាមកសាងធ្វើនឹងខំរកតែម្យ៉ាង, មិនមែនបដិសេធន៍សំណាងចោលទេ តែសូមប្រាប់ថា,អម្បាលយ៉ាងព្រះសម្ពុទ្ធជាម្ចាស់ព្រះអង្គខំកសាងបំពេញបារមីអស់ ៤ អសង្ខេយ្យ ១ សែនកប្ប, ចុះដូចម្តេច ក៏ព្រះអង្គចាំធ្វើទុក្ករកិរិយាអស់ ៦ វស្សាថែមទៀត? សូមខេមរជនទាំងឡាយ ពិនិត្យពិចារណា តាមពាក្យខាងលើនេះចុះ ៗ

ទីបំផុតនៃធម្មទេសនានេះ សូមបន់ស្រន់ថា: ឲ្យខេមរជនទាំងឡាយបានប្រកបដោយសិរីសួស្តីជោគជ័យវាសនា គ្រប់ៗគ្នាទៅហោង ៗ

ចប់

# អត្ថានុទិដ្ឋិ

## អ្នកឧកញ៉ាតិស្សរវង្សា សំ - ស៊ិន

ជាអ្នកប្រែរៀបរៀង

(តមក)

---

មនុស្សខ្លះពោលថា ព្រះនិព្វានជារបស់កណ្ដាលៗ មិនមែនយើង មិនមែនជារបស់យើង មិនមែននរណា មិនមែនជារបស់នរណា ៗ បើដូច្នោះឃើញថានៅម្ខាងម្នាក់; យើងម្ខាងព្រះនិព្វានម្ខាងគឺយើងនឹងព្រះនិព្វានផ្សេងគ្នា, ព្យាយាមលាក់បិទបាំងបៀសវាងទៅឲ្យបាន តែនឹងលាក់បិទបាំងទៅមិនរួច, ឃើញខុស, បាននិយាយមកហើយខាងដើមថា វិរាគធម៌ឬនិព្វាននោះ ជាឈ្មោះរបស់សេចក្ដីបរិសុទ្ធ ព្រោះពាក្យផ្សេងៗ ដែលជាវេវចនៈរបស់ព្រះនិព្វានបន្ទុលប្រាប់ហើយ ដូចវិសង្ខារ (អស់សង្ខារ) វិរាគៈ (អស់រាគៈ) និរោធ (រលត់) តួព្រះនិព្វានឯងនោះក៏ប្រែថារលត់ គឺរលត់កិលេសនិងទុក្ខអស់រលីងជាអាទិ៍; បើមិនមែនតួសេចក្ដីបរិសុទ្ធិហើយ តើជាអ្វីវិញ? ក្រែងសេចក្ដីបរិសុទ្ធិនោះជាលក្ខណៈអាការរបស់វត្ថុអ្វីមួយ ពោលគឺជាគុណត្រូវមាននាមគឺវត្ថុឯណាមួយត្រូវមានទីបតគុណគឺសេចក្ដីបរិសុទ្ធិនោះ នឹងនៅតាមទំនេរខ្លួនឯងមិនបានឬ?, ចុះអ្នកឯណាធ្លាប់ឃើញនៅទីណាខ្លះ ថាសេចក្ដីបរិសុទ្ធិនៅតាមទំនេរខ្លួនឯងបាន តែងត្រូវមានវត្ថុជាទីបតតាំងនោះមិនមែនឬ? ដូចសេចក្ដីបរិសុទ្ធិរបស់ទឹក សេចក្ដីបរិសុទ្ធិរបស់គ្រឿងស្លៀក

ដណ្ដាប់ ទឹងសេចក្ដីបរិសុទ្ធិរបស់កាជនៈផ្សេងៗ ជាដើម នៅដោយទំនើងខ្លួនឯងផ្សេងបាកវត្តបានកាលណា, ក៏កាលបើចូលចិត្តច្បាស់ហើយថា ព្រះនិព្វានជារបស់សេចក្ដីបរិសុទ្ធិ ជាគុណមានវត្តជាទីបតដូច្នោះហើយ យើងប្តូខ្លួននោះ ផ្សេងពីព្រះនិព្វាន ឬវិកគធម៌យ៉ាងណាក្រែងដូចគ្នាទេមិនមែនឬ? ។ សម្មតិថា យើងងូតទឹកដុសខាត់មន្ទិលញើសក្អែលកន្ទាកាយម៉ត់ចត់ស្អាតហើយ អង្គុយដេកសប្បាយ, ផលនៃការងូតទឹកគឺបានសេចក្ដីបរិសុទ្ធិ ។ ប្រសិនបើគេសួរថា សេចក្ដីបរិសុទ្ធិនោះនៅទីណា ? បើយើងមិនចង្អុលចុះត្រង់ខ្លួនយើង តើទៅចង្អុលប្រាប់ត្រង់ទីណាវិញ? ត្រូវចង្អុលចុះត្រង់ខ្លួនយើងនោះឯង ទើបទឹងឃើញសេចក្ដីបរិសុទ្ធិ ។ ប្រសិនបើគេសួរទៀត ថាយើងនោះនៅត្រង់ណា? បើមិនចង្អុលចុះត្រង់សេចក្ដីបរិសុទ្ធិ តើទឹងចង្អុលទីណា? ត្រូវចង្អុលចុះត្រង់សេចក្ដីបរិសុទ្ធិនោះទៀត ផ្ទួនចុះទៅកន្លែងទីជាមួយគ្នា ទៅណាក៏មិនរួច ។ ឧទាហរណ៍មកនេះឃើញបានថា យើងឬខ្លួនទឹងព្រះនិព្វានមានកន្លែងទីជាមួយគ្នា បំបែកចេញចាកគ្នាមិនបាន យើងក៏គឺព្រះនិព្វានៗក៏គឺយើងនោះឯង ។ កាលបើដូច្នោះ ទឹងថាយើងឬខ្លួននោះមិនមាន, ព្រះនិព្វាន ជាអនត្តា (មិនមែនខ្លួនប្រាណ) បានយ៉ាងដូចម្ដេច? ធ្លាប់ឃើញឬទេ? គេខំប្រឹងឧស្សាហ៍ព្យាយាមងូតទឹកដុសលាងញើសក្អែលទាល់តែអស់ទឹកទាំងពាង ញើសក្អែលរបស់ខ្លួនទឹងបានជម្រុះជ្រុះបន្តិច

កំណាន នៅក្រខ្វក់ស្រមូសដដែល ទៅបានសេចក្ដីបរិសុទ្ធិ៍តប់ នៅត្រង់សសរផ្ទះទៅវិញ ដែលមិនជាយើង ជាអនត្តា (មិនមែនខ្លួនប្រាណ) ៗ

អនិច្ចា:ពួកយើងក្នុងលោក អ្នកមិនមានទីពឹងនាំគ្នាបែរមុខទៅទីពឹងព្រះនិព្វានតាមព្រះពុទ្ធបរិហារ តែត្រូវអ្នកប្រាជ្ញទទឹងទាស់ក្បាលរទុកថាព្រះនិព្វានជាអនត្តាមិនមែនខ្លួនប្រាណ នាំគ្នាងាកបែរទៅតាមគ្នា, ចុះគេវិនិច្ឆ័យយ៉ាងដូចម្ដេចទើបក្លាយទៅជារឿងប្លែកដូច្នេះ? ៗ

វិភគធម៌ឬព្រះនិព្វាន ដែលជាសេចក្ដីបរិសុទ្ធនៃអសង្ខតធម៌ឬអមត-នាមធាតុនោះ ជាយើងជាអត្តា (ខ្លួនប្រាណ) ៗ និយាយស្ដាប់ងាយៗ ថាចិត្តនោះឯង ជាយើង ជាអត្តា (ខ្លួនប្រាណ) ក៏បាន តែត្រូវសំគាល់យកចិត្តបរិសុទ្ធ ជាចិត្តលោកុត្តរ: សង្ខតធម៌ដែលផ្សំអែបនែបនៅនឹងអសង្ខតធាតុនោះ ជាអនត្តា (មិនមែនខ្លួនប្រាណ) អសង្ខត-ធាតុដែលបានទទួលសេចក្ដីបរិសុទ្ធជានិព្វាន ឬជាវិភគធម៌ ហើយនោះឯង ជាយើង ជាអត្តា (ខ្លួនប្រាណ) ជាអ្នកសោយផលនៃសេចក្ដីបរិសុទ្ធិ ព្រះអង្គទើបត្រាស់ថា និព្វានំ បរមំ សុខំ "ព្រះនិព្វានជាសុខយ៉ាងក្រៃពេក" ដូច្នេះ ៗ បើយើងឬខ្លួនមិនមានទេ ព្រះអង្គត្រាស់យ៉ាងនោះក៏មិនបាន យ៉ាងដូចយើងកាលងូតទឹក ដុសក្អែលមន្ទិលធ្វើកាយឲ្យបរិសុទ្ធស្អាតហើយ ក៏និយាយថាសប្បាយឬសុខដូច្នោះ សេចក្ដីបរិសុទ្ធិនោះក៏នៅៗ ត្រង់ខ្លួនយើងនោះឯង យើងនោះឯងជាតួ

សេចក្តីបរិសុទ្ធិ នឹងជាអ្នកសោយផលនៃសេចក្តីបរិសុទ្ធិ ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់ហៅមនុស្សបរិសុទ្ធថាជាព្រាហ្មណ៍ ដូចព្រះពុទ្ធបរិហារនេះថា អនេជំ ន្ហាតកំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ សេចក្តីថា តថាគតពោលចំពោះអ្នកដែលមិនញាប់ញ័រមានខ្លួនដែលងូតលាងហើយ អ្នកដ៏នោះថាជាព្រាហ្មណ៍ ។ ព្រាហ្មណ៍ក្នុងទីនេះ គឺព្រះអរហត្តផល មនុស្សអ្នកបានអត្តាហើយ ។ តាមពិតគួរនឹងពោលថា អ្នកមិនឃើញអត្តា (ខ្លួនប្រាណ) នោះជាអ្នកអភ័ព្វ តែគេត្រឡប់ពោលថាមនុស្សដែលឃើញអត្តា (ខ្លួនប្រាណ) នោះជាមិច្ឆាទិដ្ឋិវិញ ដាក់ទោសឲ្យអង្គុយគាល់ក្បាលទង្គត់ប្រចាំលោក ទៅនិព្វានមិនបាន ត្រូវអន្ទោលវិលវល់ ដោយសង្សារវដ្ត ។ ចុះបើយើងឬខ្លួនមិនមានហើយ អ្វីទៅអង្គុយគាល់ក្បាលទង្ទត់ហ៎ះ? ចុះអ្នកឯណាជាអ្នកផុតចាកការអង្គុយគាល់ក្បាលទង្គត់ទៅបាន? គួរនឹងថាមនុស្សមិនមានខ្លួននោះឯងអង្គុយគាល់ក្បាលទង្គត់ប្រចាំលោកជាអ្នកវិលវល់ សេចក្តីឃើញក៏វិលវល់ និយាយចេញមកក៏វិលវល់ ធ្វើឲ្យអ្នកស្តាប់វិលវល់ទៀតជាចំនួនមិនតិច ក្នុងទីបំផុតទៅអង្គុយគាល់ក្បាលទង្គត់ នៅជាមួយគ្នាទាំងអស់ ។

លោកខ្លះ គាំងថាអត្តានោះ ជាបញ្ញត្តិ ឬសម្មតិ បើដកបញ្ញត្តិចេញ ហើយក៏គ្មានអ្វី ។ ដែលថាអត្តាជាបញ្ញត្តិនោះត្រូវ, តែថាដកបញ្ញត្តិហើយ មិនមានអ្វីនោះ ចាត់ថាខុស ។ ក៏វតែផ្សេងៗ

ដែលយើងឃើញ យើងត្រូវឃើញដោយភ្នែកពីរយ៉ាង គឺសាច់ភ្នែក (មំសចក្ខុ) នេះម្យ៉ាង, ភ្នែកបញ្ញាដែលហៅថា បញ្ញាចក្ខុនោះម្យ៉ាង ។ ដូចរូបផ្សេងៗ ខាងក្រៅ យើងមើលឃើញបានដោយសារសាច់ភ្នែក, តែសភាវធម៌ផ្សេងៗ ខាងក្នុង ត្រូវយើងឃើញដោយបញ្ញាចក្ខុ, ព្រះអង្គត្រាស់ដឹងជាព្រះពុទ្ធក៏ទ្រង់អាស្រ័យព្រះបញ្ញាចក្ខុ ។ វត្ថុទាំងឡាយដែលប្រាកដដោយសាច់ភ្នែកនោះ នៅមិនទាន់ចាត់ជាបញ្ញត្តិ ឬ សម្មតិទេ លុះកាលណាបានគិតនឹកតែងតាំងឡើង ឬបានបញ្ចេញសំឡេងប្រកាសឈ្មោះវត្ថុនោះៗ ឲ្យអ្នកដទៃដឹងឃើញឡើង ទើបចាត់ជាបញ្ញត្តិ ឬ សម្មតិ ។ វត្ថុកើតមុន បញ្ញត្តិ ឬ សម្មតិកើតក្រោយ តួយ៉ាងដូចពែងវត្ថុមានឡើងមុន មនុស្សទើបគិតបញ្ញត្តិហៅវត្ថុនោះថាពែង ។ បើវត្ថុនោះមិនមាន ពាក្យដែលហៅថាពែងក៏មិនមាន ។ បញ្ញត្តិនឹងកើតមុនវត្ថុមិនបានទេ បើវត្ថុមិនមាននឹងបញ្ញត្តិហៅយ៉ាងដូចម្ដេចក៏មិនបាន តែបើវត្ថុមាន សូម្បីយើងមិនបានបញ្ញត្តិហៅថាអ្វី ក៏វត្ថុនោះរមែងមានដោយប្រក្រតី ព្រោះដូច្នោះទើបថា មនុស្សដែលឃើញថាដកបញ្ញត្តិ ឬ សម្មតិហើយមិនមានអ្វីនោះជាខុសឥតត្រូវឡើយ ។ អត្តានោះជាបញ្ញត្តិពិតតែបញ្ញត្តិចុះទៅកងវត្ថុដែលមាន ។ សូម្បី អនិច្ចំ ទុក្ខំ អនត្តា នោះក៏ជាបញ្ញត្តិដូចគ្នា រហូតដល់ធម៌ពាក្យប្រដៅដទៃៗ របស់ព្រះពុទ្ធជាម្ចាស់ដូចអរិយសច្ច ៤, ពោជ្ឈង្គ ៧ ជាដើមក៏ជាបញ្ញត្តិ ។ រួមសេចក្ដីថាអ្វីៗដែលយើងនិយាយស្ដីហៅប្រើគ្នា ក៏ជាបញ្ញត្តិទាំងអស់ ។ វត្ថុនោះៗ

គ្រាន់តែប្រកាសលក្ខណៈអាការ ឲ្យយើងដឹងឃើញចំពោះខ្លួនប៉ុណ្ណោះ កាលនឹងនិយាយស្តីរកគ្នាក៏ត្រូវអាស្រ័យបញ្ញត្តិនឹងវត្ថុនោះៗ ដែលមានទៅ ៗ មនុស្សនឹងតាំងបញ្ញត្តិឡើង ឬនឹងដកបញ្ញត្តិចេញក្តី វត្ថុនោះៗក៏មាននៅដោយប្រក្រតីជាធម្មតា មិនមែនអស់សូន្យទៅ ព្រោះតែដកបញ្ញត្តិរបស់មនុស្សឡើយ ។ បើសិនជាអស់សូន្យ ក៏សូន្យទៅព្រោះហេតុនៃវត្ថុនោះឯងអស់ទៅតាមធម្មតា ។ ព្រះពុទ្ធជាម្ចាស់ទ្រង់ប្រដៅឲ្យពិចារណាឃើញតាមសេចក្តីពិតក្នុងសង្ខារធម៌ ដោយសេចក្តីជា អនិច្ចំ ទុក្ខំ អនត្តា ហើយមិនឲ្យប្រកាន់ខ្ជាប់ក្នុងសង្ខារនោះប៉ុណ្ណោះ, ធ្វើដូចម្តេចទើបត្រូវដកបញ្ញត្តិ ឬសម្មតិ ទាំងធ្វើវត្ថុដែលតាំងបញ្ញត្តិនោះឲ្យលាយបាត់សូន្យទៅផង ហើយក៏រកពិតយ៉ាងដែលថានោះគ្មាន? ។ ទោសកើតមានព្រោះប្រកាន់ខ្ជាប់ដោយខ្លួនឯង មិនមែនទោសកើតមានព្រោះសម្មតិទេ ។ ក៏កាលបើដឹងថាជាបញ្ញត្តិហើយ ហេតុដូចម្តេចទើបរើសនិយាយយកតែខាងថាមិនមែនយើង មិនមែនអត្តា (ខ្លួនប្រាណ) ហ៎?, ខាងយើងខាងអត្តា (ខ្លួនប្រាណ) និយាយមិនបាន បដិសេធខាងសង្ខារធម៌ ដោយពាក្យថាអនត្តា (មិនមែនខ្លួន) ហើយ ហេតុម្តេចមិនហ៊ានទទួលព្រះនិព្វានថាជាអត្តា?, កាលបើដូច្នោះ ក៏មិនមានឱកាសជួបខ្លួនរបស់ឯង នៅបបោសអង្អែលតែសង្ខារធម៌ ដែលមិនមែនរបស់ខ្លួនដទៃទៅ នឹងប្រតិបត្តិតាមព្រះពុទ្ធភាសិតថា អត្តា ហិ អត្តនោ

តាហៅ "ខ្លួនជាទីពឹងរបស់ខ្លួន" បានយ៉ាងដូចម្ដេច? បើថាខ្លួនរបស់ខ្លួននោះមិនមានទេ តើនឹងយកខ្លួនអំពីទីណាមកទីពឹង? ។ ព្រោះដូច្នោះទើបគួរទទួលព្រះនិព្វានជាអត្តា (ខ្លួនប្រាណ) កុំបដិសេធឡើយ, ព្រះនិព្វានជាទីពឹងដ៏ប្រសើរជាទីបំផុតហើយ តែពាក្យថាទទួលនោះមិនបានសំគាល់សេចក្ដីថា ប្រកាន់ខ្ជាប់ក្នុងពាក្យបញ្ញត្តិដែលសម្រាប់ហៅប្រើ, បើប្រកាន់មាំក៏រាប់ថាជាប់ក្នុងពាក្យបញ្ញត្តិដែលសម្រាប់ហៅប្រើ, អសង្ខតៈធាតុដែលបានសេចក្ដីបរិសុទ្ធិជានិព្វានហើយ មិនមានការប្រកាន់ខ្ជាប់ ។

មនុស្សខ្លះនិយាយថា "លះបង់វត្ថុដទៃៗហើយ ទៅប្រកាន់ខ្ជាប់ព្រះនិព្វានទៀត និយាយថាលែងក្រៅជាប់ក្នុង ។ បើប្រកាន់ព្រះនិព្វានពាក្យថាយើងក៏ត្រូវជាខន្ធ ៥ ព្រោះកើតជាតិរឡើងហើយ គឺយើងម្យ៉ាងព្រះនិព្វានម្យ៉ាង ។ កាលយើងជាខន្ធ ៥ ខន្ធ ៥ ជាយើងហើយ យើងក៏លះបង់ខន្ធ ៥ មិនបាន ព្រោះខន្ធ ៥ ជាយើងៗ ចូលទៅប្រកាន់ព្រះនិព្វាន, លុះខន្ធ ៥ បែករលត់ យើងក៏ស្លាប់តាមខន្ធ ៥, តែព្រះនិព្វានមិនមែនស្លាប់ កាលបើដូច្នោះ យើងក៏រកផុតស្លាប់គ្មានទេ, ដែលនឹងផុតស្លាប់បានក៏លុះតែយើងត្រូវជាព្រះនិព្វាន ព្រោះព្រះនិព្វានជាយើងជាអត្តា (ខ្លួនប្រាណ) ទើបនឹងបដិសេធខន្ធ ៥ លះបង់សេចក្ដីប្រកាន់បាន ។ ចុះបើយើងជាព្រះនិព្វានហើយ ទៅទាញយកព្រះនិព្វានអ្វីទៀតហ្ន៎! ព្រោះដូច្នោះដែលនិយាយថា "តទៅប្រកាន់យកព្រះនិព្វានទៀត" ពាក្យនេះខ្ញុំស្ដាប់មិនចូលចិត្តសោះ ។ (មានត)

ការបណ្តុះនិស្ស័យ

# ព្រះមហាឧត្តមវិជ្ជា ផលញាណោ ប៉ុង-ប៉ម

អាចារ្យសាលាបាលីរង វត្តបទុមវតី ក្រុងភ្នំពេញ រៀបរៀង

ឃុនបណ្ណារក្ស ប៊ូ-ប៊ូ នៅពុទ្ធសាសនបណ្ឌិត្យ អ្នកពិនិត្យកែ

(តមក)

---

ការរក្សាពាក្យនោះ គឺការប្រុងប្រយ័ត្នចំពោះតែក្នុងផ្លូវដែលត្រូវ ៗ បើអប់រំឲ្យប្រព្រឹត្តទៅក្នុងផ្លូវដែលខុស មិនមែនជាការរក្សាពាក្យទេ ៗ ព្រោះរបស់ដែលត្រូវរក្សា រមែងជារបស់មិនខុស បើខុសហើយ ក៏មិនមែនជារបស់ដែលគួររក្សា បើខំជំនះតែរក្សា ក៏មុខជាខុសទៅតាមគ្នា សូម្បីការប្រែត្រឡប់សោត បើប្រែពីត្រូវទៅរកខុស ដូចជាត្រឡប់ពីស្មោះត្រង់ទៅរកវៀច ត្រឡប់ពីសុចរិតទៅរកទុច្ចរិត ក៏ជាសេចក្តីអាក្រក់ លុះតែប្រែពីខុសមករកត្រូវ ដូចជាប្រែខ្លួនដែលអាក្រក់ឲ្យមកល្អវិញបាន ប្រែចិត្តអាក្រក់ឲ្យមកល្អបាន ឬក៏ឃាត់ចិត្តពាក់អាក្រក់បាន មិនឲ្យធ្វើតាមអំពើដែលខុស ទើបថាជាសេចក្តីល្អ ៗ ហេតុនេះ លក្ខណៈនៃសេចក្តីស្មោះត្រង់ចំពោះពាក្យដែលត្រូវរក្សាឲ្យមុឹងមាំ ទើបមានកំណត់ជា ៣ សណ្ឋាន គឺ :

១ — សំបថ ·— ការឲ្យសំដីហ្មត់ចត់របស់ខ្លួនដល់អ្នកដទៃ ជាលក្ខណៈនៃសំបថ ៗ បើពោលឲ្យសំដីហ្មត់ចត់ដល់នរណា ក៏ពោល

ដោយសុទ្ធចិត្តពិតៗ ដូចជាឲ្យពាក្យសច្ចាប្រណិធានថា "នឹងមិនធ្វើឬធ្វើ" ដូច្នេះហើយ ក៏មិនគិតបិទបាំងទុក ខំរក្សាឲ្យប្រព្រឹត្តទៅតាមសំបថនោះ ហៅថា រក្សាសំបថ ។ បើពោលស្បថ ដូចជាខ្ញុំរាជ-ការដែលធ្វើសច្ចាប្រណិធានថា "នឹងតាំងចិត្តទទួលការរាជការដែលជានាទីរបស់ខ្លួន" ដូច្នេះហើយត្រឡប់ជាមិនធ្វើតាម ហៅថាខុសសំបថ ។ បើបង្ខំចិត្តឲ្យពោល ដូចជាមនុស្សប្រព្រឹត្តអាក្រក់ លុះត្រូវអាជ្ញាគ្របសង្កត់ ក៏ចេះតែពោលស្បថទៅថា "នឹងលែងប្រព្រឹត្តដូច្នេះទៀត" តែខាងក្រោយមក ក៏ត្រឡប់ជាប្រព្រឹត្តវិញ យ៉ាងនេះហៅថា កន្លងសំបថ ជាការខូចសុទ្ធចិត្តរបស់ខ្លួនឯង ។ លោក-អ្នកទាំងឡាយ គប្បីថែរក្សាសំបថទុកឲ្យស្មើនឹងជីវិត បើទុកជាត្រូវខូចបង់ជីវិត ក៏កុំឲ្យខូចបង់សច្ចៈ ។

២— **ប្ដេជ្ញា**.— ការឲ្យពាក្យទទួលព្រមដល់អ្នកដទៃថា "នឹងធ្វើ" ឬ "នឹងមិនធ្វើ" ជាលក្ខណៈនៃការប្ដេជ្ញា ។ ពាក្យប្ដេជ្ញាដែលយើងឲ្យដល់មនុស្សដទៃនោះ ទោះឲ្យក្នុងផ្លូវធានាអះអាងថា "នឹងធ្វើ" ក្ដី ទោះឲ្យក្នុងផ្លូវលះវៀរថា "នឹងមិនធ្វើ" ក្ដី ក៏រួមហៅថា "ប្ដេជ្ញា" ដូចគ្នាទាំងអស់ ។ ការឲ្យប្ដេជ្ញាចំពោះគេយ៉ាងណាហើយខំរក្សាឲ្យប្រព្រឹត្តទៅយ៉ាងនោះ ហៅថា រក្សាពាក្យប្ដេជ្ញា ។ បើមិនរក្សាទេ ហៅថា ខុសពាក្យប្ដេជ្ញា ។ សូមលោក-អ្នករក្សាពាក្យ

ប្តេជ្ញាទុកឲ្យម៉ឺងម៉ាត់ចុះ  សូមកុំភ្លេចថា  "ធ្វើប្តេជ្ញាហើយប្រែបាក់ប្តេជ្ញាវិញ  មិនប្លែកអ្វីអំពីការណាត់អ្នកដទៃឲ្យបោកខ្លួនឯងឡើយ" ។

៣ — សច្ចា ·— ការឲ្យពាក្យយល់ព្រមដល់គ្នានឹងគ្នា ជាលក្ខណៈនៃពាក្យសន្យា ។ ការឲ្យពាក្យយល់ព្រមនោះ សូម្បីយើងធ្វើទៅដើម្បីយុំគ្រងផ្លូវច្បាប់ទំលាប់ដែលហៅថា នីតិក្រមក្តី ធ្វើទៅដើម្បីប្រយោជន៍ដទៃទៀតក្តី គង់ហៅថា សន្យាទាំងអស់ ។ សូមកុំភ្លេច ! កាលនឹងឲ្យខសន្យាដល់នរណាមួយ ត្រូវត្រួតមើលខេត្តដែននឹងអំណាចនៃពាក្យយល់ព្រមរបស់ខ្លួន ឲ្យដឹងសព្វគ្រប់សិនថាបង្អៀត ទូលាយត្រឹមណា លុះសន្យារួចហើយ ត្រូវប្រតិបត្តិតាមឲ្យបានត្រឹមនោះ កុំធ្វើទៅដោយវង្វេង ឬសន្ទិះសង្ស័យមិនជាក់លាក់ ទាំងកុំក្លែងប្រើសំនួនឲ្យហួសសេចក្តីពិត ដែលជាហេតុឲ្យអ្នកម្ខាងវង្វេងជឿតាមឬចូលចិត្តខុស ។

កាលបើយល់ព្រមគ្នាធ្វើសន្យាហើយ គប្បីរក្សាឲ្យពិតប្រាកដទៅតាមសន្យានោះ សូម្បីមិនមានសាក្សី ក៏កុំក្រឡះប្រែព្រឹត្តឲ្យខុសចាកសេចក្តីពិតក្នុងចិត្ត ដែលជាសាក្សីនៅប្រចាំក្នុងខ្លួនយើងស្រាប់នោះឡើយ ។ បើធ្វើយ៉ាងនេះបានហើយ ហៅថា រក្សាពាក្យសន្យា ។ បើមិនរក្សាទេ ហៅថា កន្លងពាក្យសន្យា ។ លោក-អ្នកគប្បីធ្វើតាមពាក្យសន្យាចុះ ដោយហោចទៅ សូម្បីអ្នកទទួលសន្យាជាអ្នកតូច

កំលោក-អ្នកកុំក្រឡះឬបំបាត់សន្យានោះចោលឡើយ ត្រូវធ្វើតែតាមខសន្យា ដើម្បីរក្សាញាតិមិត្តនិងប្រទេសជាតិស្រុកភូមិ ។ ចូរកុំទទួលខសន្យាក្នុងកិច្ចការដែលខ្លួនមិនអាចធ្វើបាន គួរប្រយ័ត្នរក្សាវាចាឲ្យគង់វង់ ប្រតិបត្តិតាមពាក្យសន្យាឲ្យខ្ជាប់ខ្ជួន ។

ក្នុងលក្ខណៈស្មោះត្រង់ចំពោះវាចាទាំង ៣ ប្រការនេះ សំបថជាពាក្យស្វាប់ក្រឡា ។ យើងស្បថយ៉ាងណា ត្រូវប្រតិបត្តិយ៉ាងនោះ នឹងក្រឡះលើកចេញមិនបាន ។ ឯប្ដេជ្ញានិងសន្យាវិញ បើអ្នកម្ខាងទៀតយល់ព្រមផង ក៏អាចលើកចោលទៅបាន ។ តែបើយល់ព្រមតែខ្លួនយើងម្នាក់ឯងទេ លើកចោលពុំបានឡើយ បើយើងធ្វើខុសមុនពេលដែលលើកចោល ឬ មុនពេលផ្លាស់ប្ដូរនោះ ទុកជាជាការគន្លងប្ដេជ្ញានិងសន្យា ។ បើលោក-អ្នកចង់ឲ្យមនុស្សទាំងពួងជឿនឹងពាក្យខ្លួនត្រូវកុំលើស កុំក្រឡះពាក្យ កុំប្រែប្រួល កុំទំលាក់ចោលឬលើកចោលនូវពាក្យសំដីរបស់ខ្លួនឡើយ ចូរមានវាចាសច្ចៈ រក្សាវាចាឲ្យមុឹងម៉ាត់ បើវាចាណាជារបស់ខ្លួន ចូររក្សាឲ្យពិតតាមវាចានោះកុំបីប្រែប្រួល ។

ស្មោះត្រង់ចំពោះការងារ — ការមាននិស្ស័យស្រឡាញ់ការងារ ធ្វើអ្វីតាំងចិត្តធ្វើពិត ៗ មានសម្បត្តិនៃសេចក្ដីព្យាយាមទាំង ៣ ប្រការ គឺការព្យាយាម ការឧស្សាហ៍ និងការភ្ញាក់រឭកហ្មត់ចត់ ដែលជាគ្រឿងលើកកំឡាំងចិត្តឲ្យរឹងប៉ឹងខ្ជាប់ខ្ជួនក្លាហាន ប្រាសចាកកុសីត-

ភាព និងការប្រអូសមិតពត់ នេះចាត់ជាលក្ខណៈនៃសេចក្តីស្មោះត្រង់ចំពោះការងារ ។ តាមពិតវិធីដែលនឹងធ្វើឲ្យយើងបានសមដូចបំណងនោះ ក៏គឺនិស្ស័យស្មោះត្រង់ចំពោះការងារ ។ និស្ស័យស្មោះត្រង់ចំ-ពោះការងារនេះ មានសេចក្តីស្រឡាញ់ការងារយ៉ាងអស់ពីចិត្ត មានការយកចិត្តទុកដាក់មែនៗ មានការទទួលភារៈ ហាក់ដូចជាចង់ប្រណាំងប្រជែង មានការតាំងចិត្តធ្វើយ៉ាងម៉ឺងម៉ាត់ និងមានការយកចិត្តទុកដាក់ពិនិត្យពិច័យយ៉ាងហ្មត់ចត់ ជាលក្ខណៈ ។ ព្រោះថាបើយើងមានការតាំងចិត្តធ្វើពិតប្រាកដនៅក្នុងទីណា ត្រូវមានផ្លូវអំណោយផលឲ្យបានសម្រេចឡើងក្នុងទីនោះ ។ ដូច្នេះ និស្ស័យនេះ ទើបរាប់ថាជាឈើច្រត់មាស សម្រាប់នាំយើងទៅកាន់ទីសម្រេចផលនៃកិច្ចការទាំងពួង ។ អ្នកប្រាថ្នាលទ្ធផលនៃការងាររបស់ខ្លួន សូម្បីនឹងធ្វើកិច្ចការណា ក៏គួរធ្វើកិច្ចការនោះឲ្យពិតៗ ។

ការងារគឺហេតុ ទុកដូចជាព្រះម្ចាស់សួគ៌ដែលបណ្តាលឲ្យកើតផល គឺប្រាក់ឬដើមទុន ។ ប្រាក់ឬដើមទុនគឺផល ទុកដូចជាបុត្រនៃព្រះម្ចាស់សួគ៌ដែលកើតមកអំពីការនិមិត្ត បណ្តាលនៃព្រះម្ចាស់សួគ៌ ។ ការប្រកបការងារ ជាហេតុបណ្តាលឲ្យក្លាយទៅជាអណ្តូងកើតនៃប្រាក់ ឬដើមទុន ។ សូម្បីប្រាក់ ឬ ដើមទុននោះ ក៏គឺផលរបស់ការងារដែលហ្មត់ចត់ ។ ហេតុនេះ កំឡាំងការងារ ទើបមានអំណាចលើប្រាក់

ឬដើមទុន ព្រោះយើងនឹងបានគ្រឿងឧបភោគ បរិភោគ គុណវុឌ្ឍិ នឹង សេចក្ដីសុខ សេចក្ដីចំរើន ត្រូវប្រើកំឡាំងការងារជានិច្ច ។ អញ្ជើញមើលចុះ សំពត់អាវគ្រឿងស្លៀកពាក់-ដណ្ដប់ប្រើប្រាស់ដ៏ល្អៗ គ្រឿងតុបតែងផ្ទះសំបែងដ៏វិចិត្រត្រកាលភ្នែក រថយន្ត រថភ្លើងនឹងអាកាសយានដែលធ្វើឲ្យការគមនាគមន៍ផ្លូវទឹកផ្លូវគោក នឹងផ្លូវអាកាសបានស្រួលទូទៅពេញលោក ។ សួនច្បារស្រែចំការដែលពីដើមងងឹតស្លុងជាព្រៃសោះ ក៏ក្លាយទៅជាទីគួររីករាយភ្លឺចិញ្ចែងដោយពន្លឺអគ្គិសនី ។ វត្ថុទាំងអស់នេះ សុទ្ធតែកើតមកអំពីកំឡាំងនៃការងារទាំងអស់ ឬសូម្បីវត្ថុនានាដទៃទៀត ក៏សុទ្ធតែជាផលនៃកំលាំងការងារដែរ ។

ធ្វើការដើម្បីទំនុកបំរុងជីវិត ធ្វើការដើម្បីកិត្តិយស នឹង ធ្វើការដើម្បីជាករណីយកិច្ច ចាត់ជាលក្ខណៈនៃការធ្វើការងារ ។ តែអ្នកដែលមាននិស្ស័យស្រឡាញ់ការងារ រមែងធ្វើការងារដើម្បីជាករណីយកិច្ច គឺធ្វើដោយឃើញថា ជានាទីដែលខ្លួនជាមនុស្សមួយដូចគេក្នុងលោកដែលត្រូវតែធ្វើ ហើយរាប់អានការងារដូចជាព្រះម្ចាស់សួគ៌ រាប់អានប្រាក់ ឬ ដើមទុន ដូចជាបុត្រនៃព្រះម្ចាស់សួគ៌ ព្រោះប្រាក់មាស ឬ ដើមទុន សម្រាលចេញមកពីការងារ ព្រមទាំងជាអ្នកចារិកឆន្ទៈ វិរិយៈឧស្សាហៈ ព្យាយាម នឹងប្រឹងប្រែងម៉ឺងម៉ាត់ទុកក្នុងប្រអប់សីសៈ ដៃជើងនឹងសរសៃនៃមនុស្សទូទៅ ធ្វើអ្វី ក៏តាំងចិត្តធ្វើពិតៗ មិនរួញរាមិនខ្ជិល

ប្រមូលមិតពត់ ធ្វើហួរហែជានិច្ច បំណងចំពោះកិច្ចដែលធ្វើជាសំខាន់ ៗ សូម្បីក្នុងខណៈដែលធ្វើ ក៏មានចិត្តប៉ុនប៉ងខ្ជាប់ខ្ជួននៅក្នុងកិច្ចនោះ ប្រៀបដូចត្រីវស័យដែលបង្អុលទៅទិសខាងជើងជានិច្ច តាំងសេចក្តីព្យាយាមពិត ព្យាយាមធ្វើរហ័សរហួនពិតៗ គ្រប់ប្រការ ដំណើរការងារតាមទំនងឫសឈើចាក់ស្រែះក្តី ឬទឹកក្នុងជ្រោះជ្រលងដែលហូរច្រោះក្តីឲ្យក្លាយទៅជាស្ទឹង នឹងធ្វើការងារដោយឆន្ទៈគាប់ចិត្ត រីករាយចិត្ត មិនគិតថាការងារនោះធ្ងន់ឬស្រាលឡើយ មិនតែប៉ុណ្ណោះ ថែមទាំងត្រឡប់ឃើញការងារធ្ងន់ ថាជាគ្រឿងបង្ហាត់និស្ស័យឲ្យល្អក្រៃលែង ធ្វើឲ្យស្គាល់ដំឡៃរបស់ប្រាក់ នឹងឲ្យចេះប្រើប្រាក់ជាប្រយោជន៍ទៅវិញ ជាអ្នកមានចិត្តមានៈ អត់ធន់ក្នុងការពាន់ពារឧបសគ្គ លះបង់សន្តានពាយមាយ និស្ស័យថោកទាបចេញ ធ្វើឲ្យទៅជានិស្ស័យល្អ អាចធ្វើកិច្ចការតូច ធំ ងាយ លំបាក ធ្ងន់ ស្រាលឲ្យសម្រេចបានទាំងអស់ ៗ

ក្រោកឡើងអ្នកកម្ពុជា !!! ចូរក្រោកឡើង ! នាំគ្នាខំបណ្តុះនិស្ស័យស្មោះត្រង់ចំពោះការងារ ! ការងារចូរជាត្រីវស័យរបស់លោកចុះ! ការងារនៅក្នុងទីណា ចូរយាត្រាឆ្ពោះទៅកាន់ទីនោះ! កុំមើលងាយការងារ ! ៗ បើលោក-អ្នកស្មោះត្រង់ចំពោះការងារហើយ អនាគតរបស់លោក-អ្នក ក៏នឹងបានភ្លឺថ្លា មានជងផ្លូវសម្រាប់ដើរទៅកាន់សេចក្តីចម្រើនក្នុងខាងមុខ ៗ មើលចុះ ការតាំងចិត្តធ្វើការងារពិតៗ

មិនខ្ជិលច្រអូស តែងក្លាយទៅជាទឹកផ្អែម តាំងពីក្រោមឡើយ ក៏ក្លាយទៅជាសំពត់ថ្មី ។ បើលោក-អ្នកមើលងាយការងារវិញ អនាគតរបស់លោក-អ្នក ក៏នឹងងងឹតឈប់ មិនមានប្រវត្តិហេតុដ៏ល្អមួយ ដែលនឹងទារកទុកឲ្យបច្ឆិមាជនតាជនជាន់ក្រោយ នឹករឭកបានឡើយ ។ កាលលោក-អ្នកស្លាប់ទៅហើយ ក៏ហើយទៅតែម្តង មិនមាននរណាស្តុតចិត្តទេ ។ ដូច្នេះ លោក-អ្នកចូរធ្វើខ្លួនឲ្យជាមនុស្សពិតប្រាកដធ្វើការងារឲ្យពិតៗ ធ្វើរបស់អ្វី ត្រូវប្រើសេចក្តីពិតតកុងរបស់នោះ កុំគ្រាន់តែជាឡើយ ត្រូវបែរមុខយកចិត្តទុកដាក់កងការងារឲ្យគប់វេលាប៉ុនប៉ងឲ្យវត្ថុដែលធ្វើនោះបានសម្រេចប្រយោជន៍ពិតៗ កុំជាមនុស្សខ្ជិលច្រអូសមិតពត់ឡើយ ព្រោះមនុស្សខ្ជិលច្រអូស ជាមនុស្សស្លាប់មុនស្លាប់ ។

មនុស្សខ្ជិលច្រអូសនោះ នឹងកើតទៅជាមនុស្សពេញទីឡើងបានលុះតែគេដឹងខ្លួនទាន់ ហើយផ្លាស់ចិត្តមកជាមនុស្សប្រឹងប្រែងរឹងប៉ឹងធ្វើការងារដោយសេចក្តីអត់ធ្មត់វិញ ។ លោក-អ្នកត្រូវផ្លាស់ចិត្តគំនិតពីសេចក្តីខ្ជិលច្រអូសមកកាន់ការឧស្សាហ៍ចុះ ត្រូវមាននិស្ស័យស្រឡាញ់ការងារឲ្យមែនទែន កុំធុញទ្រាន់ចំពោះកិច្ចការ កុំនឿយណាយចំពោះសេចក្តីលំបាក កុំរួញរាចំពោះឧបសគ្គ ចូរប្រតិបត្តិតាមច្បាប់ខាងក្រោមនេះគឺ :

១ – ត្អូងដៃប្រកបការងារ ធ្វើកិច្ចធុរៈតាមនាទីរបស់ខ្លួនកុំនៅស្ងៀមកុំជាមនុស្សទំរន់ ចូរបង្ហាត់ឲ្យខ្លួនមានកំលាំងចិត្តខែងរែង ព្រោះចិត្តដែលទំរន់ ជាកំពែងកំងខាំងសេចក្តីល្អគ្រប់ផ្លូវ ។

២ – ត្រូវបណ្ដុះឆន្ទៈឲ្យរួមគ្នាក្នុងកាលធ្វើកិច្ចអ្វីមួយ និងចម្រុះសេចក្ដីព្យាយាមទាំងអស់ក្នុងកិច្ចនោះតែម្យ៉ាង កុំពាយមាយ ឬសាព៉ៅក្នុងកិច្ចការដទៃៗ បែរមុខចំពោះតែនឹងធ្វើឲ្យកិច្ចនោះបានសម្រេច ។

៣ – ត្រូវតាំងខ្លួនទុកឲ្យដូចជាអ្នកដែលចង់ប្រជ្រៀតគេចូលទៅក្នុងចន្លោះទ្វារដែលមានពួកមនុស្សខ្ជាន់ខ្ជាប់ដូច្នោះ គឺត្រូវប្រឹងប្រែងធ្វើការងារ ពានពារឧបសគ្គដោយពេញទំហឹង កុំរួញរា ឬខ្ជិលច្រអូសនៅអង្គុយស្ងៀមឲ្យងុយងោកអណ្ដែតអណ្ដូងពាយមាយ និងកុំវង្វេងអាងលេសថាពេលសង្កត់សង្កិនពិបាកចិត្តធ្វើមិនកើត ឬមិនមានអ្វីនឹងធ្វើ កុំបន្ទោសកំណើតរបស់ខ្លួនថាមិនល្អស្មើនឹងមិត្តភក្តិ ។

៤ – បើបួរបស់ណាដែលជានាទីរបស់ខ្លួនហើយ គប្បីតាំងចិត្តធ្វើរបស់នោះឲ្យបានល្អពេញទី កុំមាក់ងាយដោយឃើញថាធាប់ដល់ហើយបង្អែបង្អង់ឡើយ គប្បីប្រញាប់ប្រញាល់ប្រកបកិច្ចនោះឲ្យទាន់កាលទាន់សម័យ ប្រយ័ត្នកុំឲ្យហួសពេលហួសវេលា តាំងចិត្តធ្វើឲ្យបានល្អយ៉ាងបំផុត ។

៥ – ប្រព្រឹត្តឲ្យខ្ជាប់ខ្ជួនក្នុងកិច្ចដែលខ្លួនប្រកប មិនត្រូវរើរុះដោះដៃក្លាម ៗ ទេ ត្រូវខំអត់ធន់ ព្យាយាមប្រកបទៅដោយលំដាប់ និងត្រូវឲ្យម៉ឺងម៉ាត់ក្នុងកិច្ចដែលខ្លួនធ្វើនោះផង ប្រយ័ត្នកុំឲ្យប្រែប្រួល គឺបើនឹងធ្វើអ្វី ត្រូវធ្វើឲ្យបានពិតៗ ។ (មានត)

# រឿងសាមកុក

## ភាគទី ១២

## ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
និងពេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ម៉ាន់ថង់ឆ្លើយថា បើលោកចង់បានខ្លួនស៊ីឡុងនោះមិនក្រប៉ុន្មានទេ ខ្ញុំបាទនឹងស៊ីឡុងជាមនុស្សធ្លាប់រាប់អានស្រឡាញ់គ្នាមកពីដើម យប់នេះខ្ញុំបាទនឹងសូមយកអាសាចេញទៅនិយាយលួងលោមយកខ្លួនស៊ីឡុងឲ្យបាន ៗ ប៊ូជូបានស្តាប់ក៏មានចិត្តត្រេកអរណាស់ហើយថា អ្នកចូរទៅគិតគូរធ្វើការតាមដំរេះប្រាជ្ញាចុះ ៗ លុះវេលាយប់ម៉ាន់ថង់ក៏តែងខ្លួនជាពាហានទៀត បន្លំចូលទៅក្នុងបន្ទាយអៀវហាង ឃើញស៊ីឡុងពាក់ក្រសអុជទៀនអង្គុយមើលសំបុត្រ ៗ ម៉ាន់ថង់ក៏ចូលទៅគំនាប់ហើយជំរាបថា តាំងពីយើងបែកបាកគ្នាមកយូរហើយ អ្នកបានសេចក្តីសុខសប្បាយទេឬ? ៗ ស៊ីឡុងបានឮសំដីក៏ងើបមុខឡើងមើល ឃើញពាហានប្លែក

មុខក៏គក់ស្លុតស្មារតី លុះប្រឹងសំឡឹងមើលច្បាស់ក៏ស្គាល់បាន ទើបសួរថា អ្នកនេះឈ្មោះម៉ាន់ថង់នៅស្រុកសាន់យ៉ុងឬ? មានការអ្វីមករកយើងថ្ងៃនេះ? ។ ម៉ាន់ថង់តបថា ខ្ញុំបាទចូលធ្វើខ្ញុំរាជការនៅនឹងចូឆូ, កាលពីថ្ងៃមិញនេះខ្ញុំបានឃើញអ្នកចេញទៅប្រយុទ្ធគានឹងទៅជូ ខ្ញុំមិនបានសាកសួររកអ្នកក្នុងវេលានោះ ព្រោះតាំងចិត្តគិតថាយប់នេះនឹងវេះចូលមករកដែលខ្ញុំមកនេះមិនមែនថាមិនខ្លាចសេចក្ដីស្លាប់ទេ ទើបបន្លំចូលមកបរតានឹងអ្នកឲ្យបាន ។ ស៊ីឡុងស្ដាប់ហើយក៏អញ្ជើញឲ្យម៉ាន់ថង់អង្គុយក្នុងទីសមគួរ ហើយថា អ្នកមានការមករកខ្ញុំនោះដោយកិច្ចធុរៈអ្វីនិយាយទៅចុះ ។

ម៉ាន់ថង់ឆ្លើយថា ខុនអ្នកជាមនុស្សមានកំលាំងខ្លាំងពូកែគ្មាននរណាស្មើសោះ ចុះវាទាស់ពីព្រោះអ្វី បានជាមកនៅក្នុងកណ្ដាប់ដៃអៀវហងហាន់សៀមជូប៉េះ ធម្មតាមនុស្សក្នុងសម័យនេះខ្ញុំយល់ឃើញថា ចូឆូជាអ្នកមានអធ្យាស្រ័យល្អប្រកបទាំងស្មារតីប្រាជ្ញាក្លាហាន មានចិត្តធូរទូលាយស្រូបយករាប់អានសេនាទាហានមិនឲ្យអនាទរសោះ កិត្តិស័ព្ទនោះអ្នកគង់ដឹងឮមកហើយ កាលអ្នកចេញទៅតយុទ្ធគានឹងទៅជូនោះ ចូឆូឃើញអ្នកក៏មានចិត្តអាណិតពន់ប្រមាណ មិនបានបើកឲ្យទាហានបាញ់ផ្ទួនថែមទៅក្រែងត្រូវអ្នកមានរបួសពិការ ទើបប្រើខ្ញុំមកបរតាអញ្ជើញអ្នកទៅឲ្យបាន ដើម្បីនឹងរាប់អានសួរសន្ទនាពន្យល់ពីផ្លូវត្រូវនិងខុស ខ្ញុំក៏ពិគ្រោះឃើញថា អ្នកនៅក្នុងទីងងឹត ចូរប្រឹងរិះគិតទៅរកទីភ្លឺស្រឡះ

ទើបដឹងសេចក្ដីសុខជាក់ច្បាស់តទៅ, ដែលខ្ញុំនាំសេចក្ដីដ៏ជ្រៅឆ្ងាយទូ-លាយមកនិយាយនឹងអ្នកដូច្នេះ ក៏ព្រោះចិត្តស្រឡាញ់រាប់អាន អ្នកត្រូវតែគិតប្រមាណឲ្យសមនឹងអធ្យាស្រ័យចុះ ។

ស៊ុឡុងបានស្ដាប់ក៏ស្ងប់ស្ងៀម ១ ស្របក់ហើយដកដង្ហើមធំរួចឆ្លើយថា ខ្ញុំដែលមកផ្ញើខ្លួននៅនឹងអៀវហាង, ហាន់សៀម ជាមនុស្សមានសតិបញ្ញាតិចនេះ នឹងគិតការអ្វីក៏មិនសម្រេចទៅបាន តែចាំចិត្តព្រោះគិតឃើញថា បានជានៅនឹងគ្នាមកយូរហើយ បើនឹងដើរចោលសោះក៏មិនគួរ ។

ម៉ាន់ចង់តបថា អ្នកមិនឮទេឬ? ពាក្យបុរាណថាទុកមក "បើសត្វនឹងធ្វើសំបុកជ្រកនៅ ក៏ត្រូវអាស្រ័យរកព្រៃស្អុក ទើបធ្វើសំបុកនៅជាសុខបាន ទោះមានខ្យល់ព្យុះបក់បោកមកប៉ុន្មាន សំបុកនោះក៏មិនជ្រុះធ្លាក់អន្តរាយ" ប្រការ ១ ទៀត ធម្មតាជាតិទាហានហើយ ត្រូវស្វែងរកនាយចៅហ្វាយដែលជាមេទ័ពប្រកបដោយចិត្តធ្ងរទូលាយ រួសរាយរាប់អានពួកក្រុមជំគួបមិនរើសមុខ ហើយចេះឧបត្ថម្ភទំនុកបំរុងអ្នកនៀយហាត់នឹងចេះចាំស្គាល់ក្បួនពិជ័យសង្គ្រាម សូម្បីសត្រូវនឹងលើកមកប៉ុនប្រមាថតិចច្រើនយ៉ាងណា ក៏មិនរួញរាញញើតកោតខ្លាច មានអំណាចនឹងការពាររក្សាសេនាទាហានមិនឲ្យអន្តរាយ បើអ្នកឯណាជួបនឹងនាយចៅហ្វាយដ៏វិសេសដូច្នេះហើយ មិនចូលទៅផ្ញើខ្លួនផងទេគឺជាមនុស្សនោះគិតខុស អំណើះតទៅមុខនឹងបានជួបតែទុក្ខ ពុំបានសុខក្សេមក្សាន្តឡើយ ។

ស៊ុឡុងបានស្តាប់សព្វគ្រប់ហើយ ក្រោកលុតជង្គង់គំនាប់ម៉ាន់ថង ហើយថា អ្នកមានប្រសាសន៍ទាំងនេះខ្ញុំពេញចិត្តណាស់ បើដូច្នេះខ្ញុំនឹងទទួលធ្វើតាមពាក្យអ្នក ។ ម៉ាន់ថងតបថា បើអ្នកនឹងដាច់ចិត្តគិតទៅធ្វើកដការជាមួយនឹងចូឆូហើយ ចូរកាត់យកក្បាលអៀវហាងទឹងហាន់សៀមយកទៅធ្វើជាជំនូនចូឆូចុះ ឈ្មោះអ្នកក៏នឹងបានគាប់ប្រសើរថ្លៃណាស់ ។ ស៊ុឡុងឆ្លើយកាត់ថា ធម្មតាបាវព្រាវដែលបានទទួលទានដុំបាយរបស់នាយចៅហ្វាយរបស់ខ្លួនហើយ បើមិនពេញចិត្តគិតនឹងនៅតទៅទេ ក៏មិនត្រូវត្រឡប់ប្រទូសរ៉ាយដល់នាយដែលឥតខុសវិញសោះ បើធ្វើដូច្នោះទុកជាមនុស្សទ្រុស្តគុណអកតញ្ញូមិនល្អសោះ ដែលអ្នកឲ្យខ្ញុំធ្វើនោះ ខ្ញុំមិនយល់ព្រមតាមផងទេ ។ ម៉ាន់ថងឮហើយសរសើរថា ខ្លួនអ្នកពេញជាមនុស្សកតញ្ញូល្អណាស់ ខ្ញុំនឹងបបួលយកតែខ្លួនអ្នកទៅនៅនឹងចូឆូចុះ ។ វេលានោះស៊ុឡុងក៏ប្រុងប្រៀបរៀបចំរបស់ទ្រព្យប្រដាប់ខ្លួនគ្រប់ផួនអស់ហើយ ក៏នាំស្ព័គ្របក្សពួកប្រហែល ៣០ នាក់លបរត់ចេញពីសំណាក់នោះចូលទៅក្នុងបន្ទាយចូឆូ ក្នុងវេលាយប់ជាមួយនឹងម៉ាន់ថង ។ ឯអៀវហាងបានដំណឹងច្បាស់ថាស៊ុឡុងនាំស្ព័គ្របក្សពួករត់ទៅចូលចូឆូហើយ ក៏នឹកខឹងខ្លាំងណាស់លើកទាហាន ១ ពាន់តាមស៊ុឡុងទៅក្នុងពេលយប់នោះ លុះទៅដល់កណ្តាលផ្លូវឃើញគំនរភ្លើងឆេះឡើងលើភ្នំភ្លឺស្រឡះ ទទួលចូឆូមើលច្បាស់ទៅឃើញអៀវហាងលើក

កងទ័ពចូលមក ចូចូក៏លើកសេនាទាហានឡោមព័ទ្ធជុំវិញ ហើយស្រែកប្រកាសថា យើងមកចាំនៅទីនេះតាំងពីព្រលប់ បើខ្លួនខ្លាំងពូកែកុំរត់ថយទៅវិញ ។ អៀវហាងឃើញទាហានចូចូឡោមព័ទ្ធដូច្នេះមិញក៏ភ័យស្លុតរន្ធត់ស្មារតី នឹងនាំទាហានរត់ទៅខាងណាក៏មិនរួចសោះ វេលានេះទទួលហានសៀមលើកទ័ពតាមមកទៀត លុះឃើញកងទ័ពចូចូឡោមព័ទ្ធអៀវហាងនៅក្នុងចំណោមដូច្នោះហើយ ហានសៀមក៏លើកពារទំលាយចូលទៅយកអៀវហាងចេញមកវិញបាន ។ ចូចូឃើញដូច្នោះខំបរពលចូលចាក់កាប់សម្លាប់ទាហានអៀវហាងស្លាប់ជាច្រើន ខ្លះដែលរស់នៅក៏ចូលមកជាពួកក្រុមខាងចូចូប្រហែល ២០០ ក្ដាយ អៀវហាងនឹងហានសៀមឃើញថានឹងតទល់ពុំបាន ក៏នាំទាហានដែលសល់នោះរត់ទៅនៅនឹងអ្នកស្រុកឯខែត្រឡាំយ៉ុង ។

ចូចូថយទ័ពត្រឡប់មកទីដើមវិញ គ្រានោះម៉ាន់ចងនាំខ្លួនស៊ុឡុងចូលទៅគំនាប់ចូចូៗ ក្រឡេកឃើញម៉ាន់ចងបានខ្លួនស៊ុឡុងមក ក៏ក្រោកទទួលស្រាកស្រួលសប្បាយឲ្យយកមាសប្រាក់នឹងសម្លៀកបំពាក់មកឲ្យជារង្វាន់ស៊ុឡុង ហើយតាំងឲ្យធ្វើជានាយទាហាន ។

ខណៈនោះ ចូចូអញ្ជើញព្រះចៅហៀនតេស្ដេចទៅដល់ស្រុកហ៊ូតោ ហើយរៀបសង់ជាទីព្រះរាជវាំង យាំងដំណាក់តាមថ្នាក់របៀបត្រៀបត្រាព្រមទាំងទីក្រឡាព្រះគំនាល់រាជរោងរម្យជុំវិញព្រះរាជវាំង តាំងឲ្យដឹក

គួរបង្ហូរទឹកព័ទ្ធជុំវិញ; ឯកំពែងទីងសែននោះមិញក៏លើកឲ្យខ្ពស់ស្រឡះ ទីងគន់មើលឃើញល្អណាស់គ្រប់ប្រាង្គប្រាសាទខាងក្នុង ព្រះចៅ-ហៀនតេទ្រង់ឡើងគង់នៅក្នុងទីព្រះរាជវាំងក្រុងហ៊ូគោនោះ ហើយតាំងឲ្យតាំងស៊ុនទីងនាហ៊ឺន ៣០ នាក់ពេញទីជាសេនាបតី ។

ខណៈនោះ ប៊ូប៊ូក៏មានចិត្តកំរើកក្រៀវក្រា និយាយរាជការពេញអំ-ណាចគ្រប់មុខក្រសួងត្បូងអ៊ាវតាំងខ្លួនឡើងជាមហាឧបរាជធំ នាហ៊ឺនគ្រប់ក្រមក៏នៅក្រោមបង្គាប់ស្តាប់ការ ។ ប៊ូប៊ូបានតាំងស៊ុនហុក, ស៊ុនស៊ីវ, គុយកៃ, ឡេវហ្វូ ទាំង ៤ នាក់នេះជានាហ៊ឺនខាងរដ្ឋបាល; តាំងម៉ាកាយ, ឡិកពោ, យិមជុន ៣ នាន់នេះជានាហ៊ឺនខាងក្រសួងឃ្លាំងទីងជង្រុកស្រូវ; ចៀយ៉ុកជាចៅហ្វាយស្រុកតាំងប៉េង អ្នកសេង ទីងតាំងជៀវជាចៅហ្វាយស្រុកឡុកអៀង ម៉ាន់ថងជាចៅហ្វាយស្រុកហ៊ូគោ, ហៃហ្វូទុន, ហៃហ្វូអៀន, ចោយិន, ចោហង ទាំង ៤ នាក់នេះជាសេនាឯក; លីយ៉យ, លីទៀន, អ៊ាក់ជិន, អ៊ីកិម, ស៊ុឡុង ៥ នាក់នេះជាសេនាទោ; ខៅជូ, ទៀនអ៊ុយ ២ នាក់នេះជាសេនាត្រី; បណ្តាសេនាទាហានដែលមានថ្វីដៃខ្លាំងពូកែទាំងអស់នេះ សុទ្ធតែតាំងជានាហ៊ឺនមានបណ្តាស័ក្តិដូចគ្នា, ឯក្នុងក្រុងហ៊ូគោនោះ បើអ្នកឯណាទីងនិយាយការរាជការអ្វីៗ ក៏ត្រូវនាំសេចក្តីនោះមកប្តឹងប៊ូប៊ូជាមុន ទើបនាំក្រាបបង្គំទូលព្រះចៅហៀនតេជាបជាក្រោយ ។ (មានត)

# រឿងអារក្សថ្លែងរឿងម្ភៃប្រាំ

## លោកសាង-សារ៉ាត លេខានុការ ក្រសួងហិរញ្ញវត្ថុ

ប្រែពីភាសាបារាំងមកជាខ្មែរ

(តមក)

## រឿងទី ៦

អារក្សនិយាយដូច្នេះថា: "ឱមហារាជ! មានទីក្រុងមួយ ឈ្មោះក្រុងធម្មបុរ: (Dharmipur) ឯព្រះចៅដែលគ្រងរាជ្យនៅក្រុងនេះ ព្រះនាមព្រះបាទធម្មសីល (Dharmshil) ស្ដេចទ្រង់មានកុង្សីយ៍មួយនាក់ ឈ្មោះអន្ធក: (Andhak) ៗ ថ្ងៃមួយនោះ លោកកុង្សីយ៍ក្រាបបង្គំទូលព្រះអង្គថា: "សូមទ្រង់ព្រះបមកពជ្រាប! សូមស្ដេចទ្រង់សាងព្រះវិហារមួយថ្វាយទៅព្រះនាងទេវី ហើយសូមព្រះអង្គស្ដេចយាងទៅចម្រើនធម៌ក្នុងព្រះវិហារនោះដរាបផង ព្រោះក្នុងសាស្ត្រា (câstras) មានចារថា កិច្ចប្រកបដោយធម៌នេះ ជាកិច្ចប្រពៃណាស់" ៗ ព្រះករុណាក៏ទ្រង់ត្រាស់បង្គាប់ឲ្យគេសង់ព្រះវិហារមួយ ហើយព្រះអង្គថ្វាយទៅព្រះនាងទេវី រួចស្ដេចបានបំពេញករណីយកិច្ចរបស់ព្រះអង្គខាងសាសនា ក្នុងព្រះវិហារនោះ តាមបែបបញ្ញត្តិរបស់គម្ពីរ ៗ មុនសូត្រធម៌ ព្រះអង្គគ្មានសោយអ្វីទេ ទោះបីទឹកក៏ទ្រង់មិនសោយដែរ ៗ លុះព្រះអង្គទ្រង់ប្រព្រឹត្តតែយ៉ាងនោះ បានបន្តិចមក ថ្ងៃមួយលោកកុង្សីយ៍ក្រាបបង្គំទូល

ព្រះអគ្គីថា: "សូមទ្រង់ព្រះចមកពព្រាប ! មានការសិតមួយដែលគេស្គាល់គ្រប់គ្នានិយាយថា ផ្ទះរបស់មនុស្សម្នាក់ៗ ដែលគ្មានបុត្រសព្រារ ផ្ទះនោះជាកលទទេស្អាត, បញ្ញារបស់មនុស្សត្រិយ ក៏ជាកលទទេ, ឯវត្តទាំងឡាយរបស់មនុស្សក្រក៏ជាកលទទេដែរ" ។

លុះស្ដេចទ្រង់ព្រះសណ្ដាប់ពាក្យអស់នោះ ព្រះអគ្គីយាងទៅកន្លងព្រះវិហារព្រះនាងទេវី ហើយបង្រួមព្រះហត្ថ តាំងបន់ស្រន់ឡើងថា: "ឱព្រះនាងទេវីអើយ ! ព្រះនាងដែលបានបំរើ វិស្ណុ (Vishnu) រុទ្រ (Rudra) និងឥន្ទ្រា (Indra) អស់ចំនួនប៉ុំពីរទិវាកត្រៃនោះ ព្រះនាងដែលបានផ្ដាញ់មារទាំងឡាយគឺ មហិសាសុរ (mahishasur) ចន្ទមុន្ទ (chand mund និង រក្ដពីជ (Raktahji) នោះ ព្រះនាងទ្រង់បានរំដោះបំទុក្ខសោកទាំងពួងដែលនៅកងភពលោកនេះ ហើយព្រះនាងតែងតែមកជួយសង្គ្រោះដល់ជនជំនិតរបស់ព្រះនាងដែលមានទុក្ខនោះ ខ្ញុំមកឱនកាយ នៅលើដំណើរវិហាររបស់ព្រះនាងហើយ ដោយមានចិត្តមិចិត្តសង្ឃឹមយ៉ាងខ្លាំងបំផុត — សូមលោកជួយធ្វើឲ្យបំណងរបស់ខ្ញុំបានសម្រេចផង" ។

កាលណាព្រះករុណាជាម្ចាស់ជីវិតលើត្បូងទ្រង់បន់ស្រន់រួចស្រេច សំឡេងមួយលាន់ឮឡើងអំពីព្រះវិហារនាងទេវី ៗ សំឡេងនោះនិយាយថា: "ឱមហាកជ ! យើងសប្បាយចិត្តនឹងអ្នកណាស់, ចូរអ្នកសុំអ្វីតាមចិត្តអ្នកប្រាថ្នាទៅមើល ?" ។

ព្រះរាជាទ្រង់មានព្រះរាជឱង្ការទៀតថា: សូមព្រះនាងជាមាតាប្រោស ! ដ្បិតព្រះនាងពេញចិត្តនឹងទូលបង្គំជាខ្ញុំហើយ សូមជួយឲ្យខ្ញុំមានព្រះរាជបុត្រាមួយអង្គផង " ។

ព្រះនាងទេវីឆ្លើយឡើងថា: "មហារាជ ! ស្ដេចនឹងមានព្រះរាជបុត្រមួយយ៉ាងពូកែ ដែលមានឈ្មោះល្បីល្បាញបំផុត" ។ ក្រោយមកព្រះមហាក្សត្រិយ៍ ទ្រង់ថ្វាយដង្វាយដែលមានឈើក្រអូប ប្រាយផ្កាទឹកអប់នឹងម្ហូបផ្សេងៗ ឯទៀត រួចព្រះអង្គទ្រង់បន់ ។ ព្រះអង្គយាងមកបន់យ៉ាងដូច្នោះរៀងរាល់ថ្ងៃ ។

កន្លងប្រាំបីទៅរាត្រីក្រោយមក ព្រះរាជបុត្រាមួយអង្គ ក៏ចាប់បដិសន្ធិកើតឡើង ។ ឯព្រះចៅធម្មសីល ស្ដេចទ្រង់នាំព្រះរាជវង្សានុវង្ស ប្រកបដោយគ្រឿងនឹងល្បែងកំសាន្តគ្រប់យ៉ាង ទៅលាបំណន់ដល់ព្រះនាងទេវី ។

មានមួយថ្ងៃនោះ អ្នកបោកខោអាវម្នាក់ ដែលមកអំពីក្រុងជិតខាង បានដើរតម្រង់ទៅក្រុងនោះ ជាមួយមិត្តសំឡាញ់របស់ខ្លួនម្នាក់ ។ លុះកាលណាបានឃើញព្រះវិហាររបស់ព្រះនាងទេវី បុរសក៏ចូលទៅថ្វាយបង្គំព្រះ ។ ក្នុងពេលនោះ បុរសបានឃើញ កូនស្រីរបស់អ្នកបោកខោអាវម្នាក់ទៀត ដែលមានរូបឆោមល្អបំណាច់ ។ លុះបានឃើញនាង បុរសក៏កក្ដៅក្ដាំងស្មារតី រួចបានដើរចូលទៅក្នុងព្រះវិហារក្នុងពេលនោះដែរ ក៏ចូលទៅលុតជង្គង់សំពះដល់ទេពធីតានឹកយ៉ាងដូច្នេះ

"ឱទេពធីតា! បើដោយអានុភាពរបស់ព្រះនាង ខ្ញុំបានរៀបការជាមួយស្ត្រីដ៏ល្អឆើតឆាយនេះ ខ្ញុំសូមថ្វាយសិរសារបស់ខ្ញុំ" ។ លុះបានសន្យាយ៉ាងនេះឡារិកដូច្នោះហើយ អ្នកសំពះរួចធ្វើដំណើរទៅកាន់ទីក្រុងជាមួយមិត្តរបស់អ្នកទៅ ។ ប៉ុន្តែ លុះបានទៅដល់ទីក្រុងនេះអ្នកកើតទុក្ខយ៉ាងធ្ងន់ ដោយសារឃ្លាតបែកអំពីនាង បណ្តាលឲ្យអ្នកខានដេក ខានផឹក ខានបរិភោគអាហារ ។ ក្នុងចំនួនប្រាំបីយប់ប្រាំបីថ្ងៃអ្នកនឹកដល់នាង ឯមិត្តរបស់អ្នក ដែលជាសាក្សីនៃព្រេងសំណាងកំសត់នេះ បានទទួលដឹងរឿងនេះ ប្រាប់ឪពុករបស់អ្នកគ្រានសល់ ។ លុះបានឮដូច្នោះ ឪពុករបស់អ្នកនេះ ព្រួយចិត្តជាខ្លាំង រួចតាំងគិតថា: "ដោយឃើញភាព ដែលកំលិចលង់នេះ បើកំមិនបាននាងនោះទេ ប្រាកដជាកំស្លាប់មិនខាន, អញត្រូវតែរៀបការឲ្យកំទៅ, គឺមានតែមធ្យោបាយមួយៈនេះទេ ដែលអាចជួយស្រោចស្រង់ជីវិតកំ" ។

លុះគិតដូច្នោះ គាត់ទៅក្នុងភូមិ ដែលឪពុករបស់នារីនៅនោះ ដោយមានកូនប្រុសរបស់គាត់ជូនទៅផង ហើយនិយាយទៅកាន់ឪពុករបស់នាងថា: 'ខ្ញុំមានកិច្ចសួរលោកបន្តិច សូមលោកយល់ព្រម រួចខ្ញុំនឹងជំរាបជាក្រោយ" ។

— បើសិនណាវត្ថុដែលលោកសុំខ្ញុំនោះ នៅក្នុងអំណាចរបស់ខ្ញុំ ខ្ញុំជូនបាន មានប្រសាសន៍មកចុះ ។

លុះបានទទួលពាក្យសន្យានេះស្រេចកាលណា គាត់ក៏សុំយុវតីឲ្យមកកូនរបស់ខ្លួន ។ ឯឪពុករបស់នាងក៏យល់ព្រម ហើយបានហៅព្រាហ្មណ៍ម្នាក់មក ព្រាហ្មណ៍នោះទាយតាមផ្កាយ កំណត់ពេលវេលាល្អរួចនិយាយថា: " ចូរនាំកូនប្រុសរបស់លោកមក រួចខ្ញុំនឹងជូនកូនស្រីរបស់ខ្ញុំ " ។

ដល់បានឮពាក្យនេះហើយ គាត់ក្រោកឡើង ត្រឡប់ទៅផ្ទះនៃខ្លួនវិញ ។ លុះកាលណាបានរៀបចំគ្រឿងប្រដាប់សម្រាប់អាពាហ៍ពិពាហ៍រួចស្រេចហើយ គាត់វិលមករៀបអាពាហ៍ពិពាហ៍កូននោះ រួចហើយត្រឡប់ទៅផ្ទះវិញ ដោយបាននាំកូនប្រុសនឹងកូនប្រសារស្រីរបស់គាត់ទៅជាមួយផង ហើយជនទាំងអស់នេះ ក៏បានរស់នៅដោយសេចក្ដីសប្បាយរីករាយតទៅ ។

កន្លងក្រោយពីនោះបន្តិចមក មានព្រឹត្តិការណ៍យ៉ាងក្សេមក្សាន្តមួយកង់គេហស្ថានរបស់ឪពុកនាងជាភរិយា គេបានអញ្ជើញជនទាំងអស់គ្នាមកផ្ទះឪពុករបស់នាងនោះ ។ ដល់រៀបចំគ្រឿងប្រដាប់ប្រដារសព្វគ្រប់ហើយ ជនទាំងអស់នេះបានទៅដល់ជិតទីក្រុងព្រះវិហារនៃព្រះនាងទេវី ក៏លេចឡើង ពីមុខអ្នកទាំងអស់ ឯកូនប្រុសរបស់អ្នកបោកខោអាវ ក៏នឹកឃើញបំណន់ ដែលខ្លួនបានធ្វើហើយ រួចនឹកគន់ចិត្តថា: " អញគ្មានគុណធម៌ទេ, ហើយអញមិនមែនស្មោះចំពោះសោះ ព្រោះអញបានថ្វាយកិច្ចសន្យាតក្កុហកមួយទៅព្រះនាងទេវី " ។ លុះគិតឃើញ

ដូច្នោះ អ្នកនិយាយទៅមិត្តរបស់អ្នកទាំងអស់ថា: "នៅហ្នឹងហើយ? ខ្ញុំទៅថ្វាយបង្គំព្រះនាងទេវីសិន រួចខ្ញុំត្រឡប់មកវិញឥឡូវនេះ" ។ អ្នកនិយាយផ្ដាំផ្ញើទៅភរិយារបស់អ្នកដូច្នោះទៀត រួចដល់ទូតទឹកក្នុងស្រះក្បែរព្រះវិហាររួចកាលណា អ្នកទៅដល់ពីមុខព្រះនាងទេវី ចប់ដៃរួចសំពះ ។ អ្នកហូតដាវរបស់អ្នកចេញ អារបំពង់កខ្លួនឯង ឯក្បាលរបស់អ្នក ក៏ដាច់អំពីដងខ្លួនមួយរំពេច ហើយធ្លាក់ដល់ដី ។...

ចំណែកខាងមិត្តរបស់អ្នក ដោយចាំយូរពេកមិនឃើញត្រឡប់មកវិញ ក៏សម្រេចថាទៅមើល តើមានរឿងហេតុអ្វី ហើយនិយាយទៅនាងស្ត្រីថា: "នៅហ្នឹងហើយ ខ្ញុំទៅរកគាត់ រួចនាំគាត់មកវិញ" ។ បុរសក៏ដើរចេញទៅបានចូលក្នុងព្រះវិហារ ស្រាប់តែភ្ញាក់ ដោយបានឃើញក្បាលមិត្តរបស់ខ្លួន ដាច់អំពីកងកាយនៅលើព្រះធរណី ។ ដល់ឃើញដូច្នោះ អ្នកគិតថា: "ភពលោកយើងនេះជាចំណងមួយពេញដោយសេចក្ដីលំបាក ។ គ្មានអ្នកណាមួយដឹងថាខ្លួនថ្វាយសិរសារបស់ខ្លួនដល់ទេវីឡើយ ។ ប៉ុន្តែ គេមុខជានិយាយថា: អញបានសម្លាប់មិត្តរបស់អញ ដើម្បីយកភរិយាដែលល្អចំណាប់នេះមិនខាន ។ ស្លាប់ទៅវិញល្អជាជាងមានកេរ្តិ៍ឈ្មោះអាក្រក់ក្នុងស្ថានកណ្ដាលនេះ" ។ លុះនិយាយដូច្នោះហើយ អ្នកចុះទៅលុបលាងកាយ រួចចូលទៅនៅពីមុខទេពធីតា សំពះព្រះនាង ហើយសូត្រធម៌ ។ រួចអ្នកទាញដាវរបស់អ្នកមកកាត់ក្បាលខ្លួនឯងទៅ ... ។

ចំណែកខាងនាងស្ត្រី ចាំមើលផ្លូវដកប ៗ ដោយគិតថ្ងៃផងដោយធុញទ្រាន់ឃ្លាំមើលផ្លូវផង ដោយអស់សង្ឃឹមថាបានជួបប្ដីរបស់នាងវិញផង នាងក៏ដើរទៅរក ដល់ចូលទៅក្នុងព្រះវិហារ នាងព្រឹអស់អង្គកាយ ដោយបានឃើញខ្មោចទាំងពីរសន្ធឹងនៅលើដី ៗ កាលណាឃើញខ្មោចនេះរួច នាងគិតហើយនិយាយថា "អ្នកទាំងពួងមិនជឿថា បុគ្គលទាំងពីរបានធ្វើពលីកម្មថ្វាយជីវិតដល់ព្រះនាងទេវីនោះទេ ប្រាកដជាគេនិយាយថាស្រីមេម៉ាយត្រីយ៍នេះ បានធ្វើឃាតកម្មដល់ជនទាំងពីរមិនខានដោយប្រាថ្នាចង់ធ្វើអាក្រក់ដល់ជននោះ ៗ ដូច្នេះអញគួរស្លាប់ទៅល្អជាជាងមានកេរ្តិ៍ឈ្មោះបែបនោះ" ៗ

លុះគិតដូច្នោះហើយ នាងទៅសំពះពីមុខទេពធីតា កាលណានាងទៅលុបលាងខ្លួនរួច លើកដាវបំរុងនឹងសម្លាប់ខ្លួនឯង ស្រាប់តែព្រះនាងទេវីចុះពីលើស្ទូតច្រូតមក ចាប់ដៃនាងជាប់ ហើយនិយាយថា: "កូនស្រីសម្លាញ់? ចូរឯងសុំអនុគ្រោះមួយអំពីយើងចុះ ព្រោះយើងពេញចិត្តនឹងឯងណាស់" ៗ

នាងឆ្លើយទូលទៅព្រះនាងទេវីថា: "ឱព្រះមាតាទូលព្រះបង្គំអើយ! បើព្រះអង្គពេញព្រះរាជហឫទ័យនឹងទូលព្រះបង្គំជាកូនហើយ សូមព្រះអង្គប្រោសជនទាំងពីរនេះឲ្យរស់ឡើងវិញ" ៗ

នាងទេពធីតា បង្គាប់ឲ្យនាងយកក្បាលទៅដាក់លើដងអង្គកាយរៀងរាល់រូបវិញ ៗ នាងអររន្ធត់ខ្លាំងពេក ទៅដាវិលគំនិតអស់ នាំ

ឲ្យនាងប្រឡំហើយ ដាក់ក្បាលមិនត្រឹមត្រូវទៅលើរូបវិញ ។ ឯព្រះនាងទេវី ដល់យកទឹកអប់ព្រោះទៅជនទាំងពីរមានជីវិតក្រោកឡើង ហើយតាំងប្រណ្ដោះគ្នា ។ ម្នាក់ៗ និយាយថា: "នាងជាប្រពន្ធអញ នាងជាប្រពន្ធអញ" ។

លុះនិទានដូច្នោះហើយ អាវក្សក្រាបបង្គំទូលសួរថា: "ឱមហារាជ! តើអ្នកណាជាប្ដីរបស់នាង ក្នុងបណ្ដាជនទាំងពីរនេះ" ។

ឯព្រះចៅក្រុងមានព្រះរាជឱង្ការតបវិញថា: "ចូរឯងស្ដាប់? គម្ពីរមានបាលថា ទន្លេគង្គា (gange) ធំជាងទន្លេទាំងអស់, គិរីឈ្មោះសុមេរុ (sumêru) ជាគិរីថ្លៃថ្លាជាងគិរីទាំងអស់, ដើមកល្បព្រឹក្ស (kalpaVrish) ឈ្មោះដើមឈើមួយដែលនៅស្ថានព្រះឥន្ទ្រ ហើយមានអំណាចអាចឲ្យមនុស្សដែលចង់បានអ្វីបានទាំងអស់, ជាដើមឈើលេខមួយ ក្នុងបណ្ដាដើមឈើទាំងអស់ ឯក្បាលជាអវៈយវៈមួយដែលមានប្រយោជន៍ជាងអវៈយវៈទាំងអស់ ។ ហេតុដូច្នេះនាងនោះ ជាប្រពន្ធរបស់បុរសដែលមានក្បាលរបស់ប្ដីនាង" ។

លុះឮព្រះរាជឱង្ការដូច្នោះ អាវក្សត្រឡប់ទៅព្យួរខ្លួននៅលើដើមឈើៗ ឯមហាក្សត្រិយ៍ ស្ដេចទ្រង់ថយទៅយកមកវិញ ចងអាវក្សនោះហើយ លើកអាវក្សដាក់លើអង្សា ហើយយាងទៅ ។

ចប់រឿងទី ៦, នៅមានរឿងទី ៧ តទៅទៀត ។

## រឿងស្នេហាជាតិ

### លោក គង់-លឹម និស្សិតសាលាគរុវិជ្ជា ភ្នំពេញ តែង

(តមក)

---

### ឈុតទី ២ ឆាកទី ១

### វណ្ណ៍តាភ - វណ្ណ៍នារី - ភាណារុទ្ធិ

#### វណ្ណ៍តាភ

សេចក្តីក្លាហានចិត្តមុតថ្លា    អាចសម្រេចការគ្រប់ជំពូក
សម្រាប់ជិះធ្ងន់ដូចជាទូក    ថែវចូកទៅកាន់ត្រើយនាយបាន ៗ
ជាតិនេះកើតមកខ្លួនជាស្រី    ប្រាថ្នាតែប្តីចិត្តក្លាហាន
ឱ! ទេវតាអើយជួយឲ្យបាន    រូមប្រាណដូចចិត្តខ្ញុំប៉ុនប៉ង ៗ
សូមព្រះរតនត្រ័យបីប្រការ    សម្រេចផលាខ្ញុំបំណង
បានប្តីក្លាហានខ្ញុំឥតហ្មង    ខ្ញុំផ្សងសច្ចាសូមសម្រេច ៗ

(វណ្ណ៍ធារីចេញ)

ឱ! នាងវណ្ណ៍នារីអូនពីសី    អូនចង់បានប្តីយ៉ាងដូចម្តេច?
សូមនាងប្រាប់បងឲ្យដឹងកិច្ច    បងជួយសម្រេចដូចប្រាថ្នា ៗ

#### វណ្ណ៍នារី

រូបកាយនៃមនុស្សខុសគ្នាច្បាស់    មារយាទចំណាស់ចិត្តចិន្តា

ខ្ញុំសូមជំរាបបងវណ្ណ៍តារា    បងខ្ញុំហើយណា ! ទើបហ៊ានប្រាប់ ។
សូមបងប្រណីអភ័យទោស    បើចិត្តខ្ញុំខុសពីសូរស័ព្ទ
វាចាផងបងខ្ញុំបានស្ដាប់    សូមបងកុំចាប់ប្រកាន់ខឹង ។

វណ្ណ៍តារា

និយាយទៅចុះមិនថាអ្វី !    វណ្ណ៍នារីអូនស្រីស្ងួនព្រលឹង
ថ្លែងវាចាចុះឲ្យបងដឹង    បងមិនខឹងទេណាប្អូនស្រី ! ។

វណ្ណ៍នារី

បងមិនគួរថ្លែងវាចា    ខ្មាសអស់ទេវតាកតទាំងបី
ស្រីជំនុំគ្នាគិតរកប្ដី    គួរអី ! ខ្លួនខ្ញុំសែនចំបែង ។
កិច្ចការរៀនសូត្រធ្វើព្រងើយ    កន្ដើយមកគិតឯគ្រឿងល្បែង
តណ្ហាសម្រើបចិត្តជនក្មេង    សង្រែងរូបកាយដោយស្នេហា ។

វណ្ណ៍តារា

នែ ! ប្អូនកុំគិតទៅវែងឆ្ងាយ    គិតក្ដីរៀងអាយនេះសិនណា
ឯកាមរាគនឹងតណ្ហា    មនុស្សក្មេងលោកាមានគ្រប់ថ្នាក់ ។
ខំរៀន ខំសូត្រ ខំធ្វើការ    បំពេញតណ្ហានឹងរាគៈ
ត្រង់នេះសូមប្អូនជឿឲ្យជាក់    កំឡាំងរាគៈរបស់បង ។

វណ្ណ៍នារី

រាគៈ ឬកាមនឹងតណ្ហា    គ្មានអ្វីអស្ចារ្យនូវបំណង

គឺជាចិត្តហើយដែលចម្បង   ចំណងអ្វីៗធំពុំស្មើ ។

វណ្ណ៍តារា

ចិត្តធំជាងខ្លួនឬរូបកាយ   វណ្ណ៍នារីឆោមឆាយប្រាប់មកមើល៍
តើប្តីដូចម្តេចដែលប្រសើរ   នាងស្មើប្រាប់មកកុំខ្មាសអ្វី ! ។
ទាន់ម៉ាក់មិននៅស្រួលនិយាយ

វណ្ណ៍នារី

បងអើយចិត្តខ្ញុំស្រឡាញ់ប្តី
ដែលភាពល្អល្អះទន់សំដី   និយាយអ្វីពាក្យផ្អែមល្ហែមគួរស្នេហ៍ ។
ទាំងឫកកិរិយាក៏សុភាព   រាបទាបសមឫកជាកូនខ្មែរ
ស្លូតត្រង់ត្រឹមត្រូវឥតបែកបែរ   គ្នាន់គ្នេររក្សាសត្យសេចក្តី ។

វណ្ណ៍តារា

វណ្ណ៍នារីអូនឯងនៅក្រោយណាស់   មិនទាន់យល់ច្បាស់ស៊ីវឡៃ
គេលែងយកហើយភាពបែបប្តី   ដែលឯងស្រដីមកនេះណា ។

វណ្ណ៍នារី

ស៊ីវឡៃ ! ស៊ីវឡៃតែបងចុះ !   មិនះឃើញកំឡោះហើយស្នេហា
ប្រុសព្រាលគោងភាពចិត្តហានក្លា   មិនមានត្រូវការមេត្រីឡើយ ។
ក្លាហានចិត្តមុតឥតមានស្នេហ៍ !   មិនបែរមើលមុខមិនកៀកកើយ
មិនត្រកត្រអាលទៅបក់បើយ   កៀកកើយជាប្តីនាំទុក្ខធំ ។ (ចេញមួយៗ)

### វណ្ណតារា

ប្ដីចិត្តក្លាហានមិនខ្លាចស្លាប់ គឺជាគូគាប់របស់ខ្ញុំ
នាងអើយចិត្តឯងនៅប្រែប្រួល គិចយ៉ំ ! ខ្ញុះ ! ប្ដីចិត្តអាចារ្យ ៗ

### ភាណរិទ្ធិ

អ្នកនាង ! ម៉ាក់នាងនៅប្តុះទេ ? (គោះទ្វារ)

### វណ្ណតារា

អ្នកមិននៅទេ អ្នកមានការ
អញ្ជើញជូនមាខ្ញុំទៅផ្សារ តើលោកមានការដូចម្ដេចនែ ! ៗ

### ភាណរិទ្ធិ

ឱ ! នារីស្រីស្រស់ឆោមឆាយ ចិត្តខ្ញុំសប្បាយពុំសំដី
នាងថ្ងៃនេះកាលណាគួរពិសម័យ អាល័យស្រឡាញ់កាន់តែខ្លាំង ៗ

### វណ្ណតារា

លោកមានសេចក្ដីស្ម័គ្រស្នេហា ទឹងនាងវណ្ណតារាពេញកំឡាំង ?

### ភាណរិទ្ធិ

វិញ្ញាណផងបងតែងកាន់កាំង . . . ក្ដួចក្ដាំងគិតដល់តែនាងថ្ងៃ ៗ

### វណ្ណតារា

បងស្រឡាញ់ ខ្ញុំឥតបើដឹង ប៉ុណ្ណឹងចិត្តខ្ញុំឥតសង្ស័យ
បើបងក្លាហានចិត្តសម័យ សូមបងលកលៃជួយខ្ញុំផង ! ៗ

## ភាណរិទ្ធិ

ធន់អ្វីមិនស្មើធន់ស្រែប្រៃ (សប្បាយ) អាចរុករកានដើរឥតសៅហ្មង
វណ្ណតាពអូនអើយសូមប្រាប់បង សម្រេចបំណងជូនប្អូនបាន ! ។

## វណ្ណតារា

បង ! ខ្ញុំមានទុក្ខធំអនេក ទ្រូងខ្ញុំស្ទើរបែកចិត្តរំខាន
ឪពុកខ្ញុំ វៀតមិញចាប់បាន ទៅឃុំឃាំងប្រាណនឹងប្រហារ ។
សូមបងអញ្ជើញទៅធ្វើសឹក សង្គ្រាមពន្លឹកដោះយកប៉ា ! . .
ឲ្យរួចពីដៃយួនមោហា វណ្ណតាពខ្ញុំព្រមជាគូគាប់ ! ។
អញ្ជើញទៅអ្នកប្រុសប្រសើរ

## ភាណរិទ្ធិ (គ្រវីក្បាល)

ប្អូនអើយនាងប្រើបងឲ្យស្លាប់
ចុះបើបងទៅយួនវាចាប់ សម្លាប់បងចោលក្បែរដីវ៉ា ។
ខានរួមស្នេហានឹងប្អូនស្រី នាងនឹងយកប្តីមួយទៀតណា
បើបងទៅស្លាប់បងអាសា គ្មាននរណាមួយនឹងឈឺផ្សាល ។

## វណ្ណតារា

អញ្ជើញទៅចុះកុំខ្លាចស្លាប់ . បើយួនវាចាប់ខ្ញុំគោរក្បាល
កាន់ទុក្ខឲ្យបងឲ្យអស់កាល បំណាច់ត្រែអាលនឹងរូបខ្ញុំ ។

ភាណារិទ្ធិ (ឈរជញ្ជឹង)

បងមិនបានទៅទេប្អូនស្រី　សឹកសង្គ្រាមជ័យចម្បាំងធំ
បងមិនទៅទេនាងក្រមុំ　កុំប្រើកែវបងឲ្យទៅស្លាប់ ។

វណ្ណតារា

កើតមកជាមនុស្សមិនត្រូវញ៉ាក　ទោះក្រលំបាកវេញ្ញាគិតអាប់
សូមអ្នកចាកចេញទៅឲ្យឆាប់!　គិតខ្ញុំបង្អាប់ខ្មាសទេវតា ។

ភាណារិទ្ធិ (លុតជង្គង់អង្វរបើបាតដៃ)

អ្នកនាងខ្ញុំសូមអង្វរចិត្ត　សូមប្អូនអាណិតចិត្តស្នេហា
បងស្រឡាញ់ស្គមអស់កាយា　វណ្ណតារា! អ្នកស្រីថ្លើមជីវិត ។
សេចក្តីរៀនសូត្រក៏អាក់ខាន　អាហារមិនបានចម្បែងចិត្ត
ស្រឡាញ់ប្អូនស្រីបណ្តូលចិត្ត　យប់បងគេងគិតមិនលក់ទេ ។
សូមនាងមេត្តាសង្គ្រោះបង　ស្រស់កែវនួនល្អងគិតគ្នាន់គេ
គឺរូបអូនហើយល្អលើសគេ　ធ្វើឲ្យបងត្រេកសែនស្រឡាញ់ ។

ឈុតទី ២ ឆាកទី ២

## វណ្ណតារា–ផលនារី–ភាណោនរា

ផលនារី

អ្នកបង! បងវណ្ណនារីនៅទេ?　ខ្ញុំមករៀនដេរ នឹងអ្នកបង!
រៀនប៉ាក់ជរផ្កាជាកម្រង　យ៉ាងល្អឥតគ្មានណាបងអើយ ។

វណ្ណតារា

វណ្ណនារី នៅហ្នឹង ! អម្បាញ់មិញ   ឥឡូវគេចេញទៅណាហើយ
ប្អូនចាំមួយភ្លែតមិនយូរឡើយ   បងទៅណាហើយកែវបណ្ដូល ។

ភាណាសា   (ចូលគប់ទ្វារ)

អ្នកនាង អ្នកនាងវណ្ណតារា

វណ្ណតារា

នរណា ! នរណា ! អញ្ជើញចូល
យើបងភាណានកសាប់ត្រសូល...   មុខមូលម្ដេចស្គមយ៉ាងនេះណា?... ។

ភាណាសា

នាងមិនជ្រាបទេកិច្ចសង្គ្រាម   យកឈាមទៅក្រាលផែនពសុធា
ការពារក្ដីសុខក្នុងភាព   កម្ពុជាសព្វថ្ងៃតើយ៉ាងណា ។
កាលដែលពីខ្ញុំទៅតស៊ូ   យកជីវិតប្ដូរសងរដ្ឋា
ជាមួយនឹងខ្មាំងគឺបច្ចា-   មិត្រយួនមោហាអង់អាចក្រៃ ។
វាចាប់សម្លាប់ជនជាតិខ្មែរ   នៅឯទល់ដែនប៉ែកខាងព្រៃ-
វែង ! ដែនខ្មែរខ្លាំងលើសលប់ក្រៃ   តអស់វាត្រីបីអស្ចារ្យ ។
ហាលភ្លៀងហាលខ្យល់ឥតមានឈប់ ថ្ងៃបីគំរប់នឹងបច្ចា-
មិត្រថយក្រោយវិញ ! ចាប់ប្រហារ ជាតិខ្មែរនានានៅទល់ដែន ។

ឳ! សែនវេទនាពេញអស្ចារ្យ ដុតដួះគេហាឥតសល់សែន
ខ្មែរនៅទល់ដែនវេទនាមែន ខ្ញុំសែនជាទុក្ខក្រៃករហាម ។

## វិណ្ណតារា

រូបខ្ញុំជាស្រីធ្វើម្ដេចម្ដា ទើបបានធ្វើការខាងសង្គ្រាម
ជួយធ្វើការបងទឹងសងឈាម ទ្រូមចូលលុកឥតភ័យកិត ។
កងទ័ពជាពលប្រសើរថ្លៃ ជាតិខ្មែរទាំងថ្លៃគួរប្រឹងគិត
ចូលធ្វើទាហានថ្លៃនៅចិត្ត ប្រយុទ្ធប្រឹងប្រិតយ៉ាងពេញទី ។

## ភាណារា

រូបនាងជាស្រីចំធ្វើការ នៅកងរដ្ឋាឲ្យសួស្ដី
ទុកឲ្យបងរក្សាផែនដី ខ្លួននាងជាស្រីចំធ្វើការ ។ (ញញឹមស្ទុះទៅឱប)

## វិណ្ណតារា

បង! ហើយថ្ងៃមជីវិតខ្ញុំ (ផលនារីអៀនរត់ចូលក្នុង)

(មានត)

# រឿងប៉ូលនិងវីរ៉ស៊ីនី

## លោក ផេង-ជ្រី វិសាស្ត្រាចារ្យ នៅសាលាគរុវិជ្ជាភ្នំពេញ

ប្រែរៀបរៀង

(តមក)

---

នៅកន្លែងនុះ ទទួលមានស្រីមេម៉ាយម្នាក់ទៀត អាស្រ័យនៅប្រហែលមួយឆ្នាំមកហើយ ។ នាងនេះឈ្មោះម៉ារ៉ាគ្រីត ។ កាលពីដើម ខ្លួននាងជាស្រីអ្នកស្រែ នៅស្រុកព្រេតាញ ។ មានកុដុម្ពិកម្នាក់ចង់បាននាង បំរុងនឹងរៀបការយកធ្វើជាភរិយាត្រឹមត្រូវ ។ តែខាងក្រោយដែលបានប៉ះពាល់ដល់ខ្លួនប្រាណគ្នានឹងគ្នាវេលាណា គេក៏រត់បោលនាងបាត់ទៅ មិនគិតដល់នាងមានកូនក្នុងពោះ ។ នាងខ្មាសគេក៏រត់បោលស្រុកអាត្មាមកនៅក្នុងកោះហ្នឹង ជាមួយនឹងព្នងប្រុសម្នាក់ ។ នាងឡាតួរដើរតាមខ្ញុំស្រីទៅៗ បានប្រទះឃើញនាងម៉ារ៉ាគ្រីត កំពុងបំបៅកូន, នាងឡាតួរសប្បាយចិត្តនឹងបានជួបស្រីដែលមានវាសនាដូចខ្លួន ។ នាងនិយាយដំណើរដើមទង និងសេចក្ដីត្រូវការនៃខ្លួនប្រាប់ដល់នាងម៉ារ៉ាគ្រីត ។ បានស្ដាប់រឿងសព្វគ្រប់ហើយ នាងនេះមានសេចក្ដីមេត្តាដល់នាងឡាតួរពន់ពេក ។ ដោយសេចក្ដីទុកចិត្តនឹងសេចក្ដីស្នេហា នាងម៉ារ៉ាគ្រីត និយាយរឿងរបស់ខ្លួនប្រាប់ដល់នាងអាគន្តុកាថា: "ខ្ញុំដែលលំបាកយ៉ាងនេះ គឺសមនឹងពុតរបស់ខ្ញុំ តែចំណែកខាងអ្នកដែលជាមនុស្សត្រឹមត្រូវ មិនគួរឡើយមកសមមានទុក្ខយ៉ាងដូច្នេះសោះ" ។

នាងម៉ារគ៉ារីតសុំនាងឡូត្តរធ្វើជាសំឡាញ់ រួមសុខរួមទុក្ខជាមួយគ្នា ។ នាងនេះត្រេកអរពន់ពេក ទើបលាន់មាត់ថា "ព្រះជាម្ចាស់ឲ្យខ្ញុំផុតពីសេចក្ដីទុក្ខត្រឹមហ្នឹងហើយ បានជាបណ្ដាលអ្នកជាមនុស្សដទៃសោះឲ្យមានចិត្តល្អ ចិត្តមេត្រីដល់ខ្ញុំឯងដែលកំពុងមានទុក្ខពេញខ្លួន ។

ពិតមែនជាខ្ញុំ (តាចាស់) នៅឆ្ងាយពីទីនេះប្រហែលជាងប្រាំមួយគីឡូម៉ែត្រ នៅខាងក្រោយភ្នំឡុងឯណោះ ខ្ញុំក៏ស្គាល់នាងម៉ារគ៉ារីតដែរ ហើយខ្ញុំទុកនាងនេះជាមនុស្សជិតខាងរបស់ខ្ញុំ ។ នៅឯក្រុងអឺរ៉ុប គ្រាន់តែថ្នល់មួយ ឬ កំពែងមួយនៅឃាំង អាចហាមឃាត់មិនឲ្យពួកសាច់ញាតិត្រកូលបានជួបជុំគ្នាអស់ឆ្នាំជាច្រើន នៅស្រុកអនាទិគមមិនដូច្នោះទេ បើគ្រាន់តែបាំងគ្នាដោយព្រៃ ឬ ដោយភ្នំមួយ អ្នកស្រុកក៏អាចរាប់អានគ្នាជាបងប្អូន ជាអ្នកជិតខាងដែរ ។ ក្នុងជាន់ដែលអ្នកកោះហ្នឹងមិនទាន់សូវធ្វើជំនួញទៅប្រទេសក្លិង្គ អ្នកជិតខាងក្នុងកោះសុទ្ធតែស្រឡាញ់រាប់អានគ្នា ហើយតែងតែជាទីសំណាក់អាស្រ័យ ដ៏សប្បាយដល់ជនបរទេសដែលជាអ្នកជំនួញ ។ កាលណាខ្ញុំដឹងថានាងម៉ារគ៉ារីតមានមិត្តសំឡាញ់ ខ្ញុំក៏មកជួយរាប់អាន ជួយទុកធុរៈដល់នាងទាំងពីរណាដូចណា ។ លុះខ្ញុំដឹងថានាងឡូត្តរជិតនឹងសម្រាលកូន ខ្ញុំប្រាប់នាងទាំងពីរឲ្យបែងដីចែកគ្នា ដើម្បីទុកឲ្យជាប្រយោជន៍ដល់កូនរៀងខ្លួនឲ្យហើយ ខ្លាចក្រែងលោអ្នកស្រុកមកកាត់យកអស់ ចំណែកមួយនៅ

ខាងលើទឹក ចំណែកមួយទៀតនៅខាងក្រោម ៗ ដល់រៀបចំស្រេច ហើយ ខ្ញុំឲ្យនាងទាំងពីរចាប់ស្នាក ៗ ដល់លើធ្លាក់បានទៅនាងឡាតួរ នាងម៉ារគីរីត បានដីខាងក្រោម ៗ ស្ត្រីទាំងពីរពេញចិត្តនឹងភាគដីរបស់ខ្លួន ៗ តែនាងសុំកុំឲ្យបែកទីលំនៅពីគ្នា ព្រោះនាងនិយាយថា គ្រាន់បើយើងនឹងបានឃើញគ្នា បាននិយាយគ្នា ហើយនឹងបានជួយធុរៈគ្នាទៅវិញទៅមក តែត្រូវនៅផ្ទះផ្សេងគ្នា ៗ ខ្ញុំសង់ខ្ទមឲ្យនាងម៉ារគីរីតមួយនៅលើព្រំដីចំពាក់កណ្ដាល ហើយសង់ខ្ទមមួយទៀតឲ្យនាងឡាតួរ នៅលើដីរបស់នាង តែជិតគ្នានឹងនាងម៉ារគីរីត ៗ ខ្ញុំខំទៅយកស្លឹកគ្រឡះតាំងពីមាត់សមុទ្រមក ដើម្បីធ្វើខ្ទមឲ្យស្ត្រីទាំងពីរ ៗ ឥឡូវនេះ អ្នកមើលចុះគ្មានអ្វីនៅសល់សោះទេ ហិនហោចអស់ហើយ ពេលវេលាតែងបំផ្លាញទីលំនៅឲ្យវិនាសឆាប់ណាស់ ៗ នៅតែចិត្តខ្ញុំទេ ដែលតែងរលឹកអំពីរឿងនេះ អស់មួយជីវិតមិនចេះភ្លេច ៗ

ខ្ញុំគ្រាន់តែធ្វើខ្ទមទាំងពីរទើបនឹងហើយ នាងឡាតួរក៏សម្រាលកូនមកគឺកូនស្រី ៗ ខ្ញុំជាឪពុកធម៌របស់កូននាងម៉ារគីរីត កុមារនុ៎ះឈ្មោះប៉ូល ៗ នាងឡាតួរ អង្វរខ្ញុំឲ្យៗ នាមដល់កូនរបស់នាង ឲ្យសមគ្នានឹងនាមរបស់កូននាងជាសំឡាញ់នៃនាង ៗ នាងម៉ារគីរីត ឲ្យហៅថា វីរស៊ីនី ៗ

កាលនាងឡាតួរ ចេញពីអាំងភ្លើងហើយ ស្ត្រីទាំងពីរតាំងផ្ដើមចាប់ធ្វើការរកស៊ី ៗ ខ្ញុំជួយម្ដងៗទេ ក្រៅពីនោះ ស្រេចតែលើគ្នាពីរនាក់

ធ្វើទាំងអស់ ។ តាព្នងជាបាវបំរើរបស់នាង ម៉ារគីរីត ឈ្មោះឌូម៉ាំង គាត់នេះពិតមែនតែចាស់ តែនៅមានកំឡាំងច្រើន ហើយឆ្លាតរកទទួលទានណាស់ ។ គាត់ដាំដំណាំច្រើនមុខផ្សេងៗគ្នា តាមទំនងដី ពោតត្រង់កន្លែងមិនសូវមានដី ស្រូវប៊ើត្រង់ដីល្អ ស្រូវធម្មតាត្រង់ដីទំនាប ត្រសក់ ឃ្លោក ត្រឡាច នៅកៀនថ្ម ដើម្បីឲ្យវាវារឡើង ដំឡូងត្រង់ដីទឹកមិនដែលលិច ដើម្បីឲ្យវាផ្អែម កប្បាសនៅទំនួល អំពៅត្រង់ដីខ្ទាំង កាហ្វេនៅលើខ្នងភ្នំតូចៗ ចេកបណ្ដោយតាមមាត់ស្ទឹង នឹងនៅជុំវិញផ្ទះ ដើម្បីឲ្យបានម្លប់ផង ដាំថ្នាំខ្លះ ដើម្បីជក់កែអផ្សុកខ្លួនឯងនឹងម្ចាស់ ។ គាត់ទៅកាប់ឧសឯព្រៃភ្នំ ទៅយកថ្មមកធ្វើថ្នល់គ្រាន់ដើរ ។ គាត់ធ្វើការទាំងអស់នេះដោយយកចិត្តទុកដាក់នឹងដោយការប្រឹងប្រែង ។ គាត់ស្រឡាញ់នាងឡាតួរ នឹងនាងម៉ារគីរីត ស្មើភាគគ្នា ។ គាត់រៀបការនាងព្នងជាបាវបំរើរបស់នាង ឡាតួរ ធ្វើជាប្រពន្ធ នៅថ្ងៃកំណើតនាងវីរស៊ីនី ។ តាព្នងស្រឡាញ់ប្រពន្ធគាត់ណាស់ នាងនេះឈ្មោះ ម៉ារី កើតនៅប្រទេសម៉ាដាកាស្កា ឆ្លាតចេះត្បាញកញ្ជើល្អ សំពត់ គួរជាទីស្នេហាដល់នាយចៅហ្វាយ ។ នាងម៉ារីជាអ្នកចាត់ចែងខាងខាទនិយភោជនីយាហារ ចេះចិញ្ចឹមមាន់ទា ហើយនឹងជាអ្នកទៅទិញអីវ៉ាន់បន្តិចបន្តួចឯផ្សារពោរ.លួី ៗ មិនតែប៉ុណ្ណោះសោត ថែមទាំងមានចិញ្ចឹមពពែពពេរសំរាប់ឲ្យកូនក្មេងឃ្វាលលេង នឹងឆ្កែមួយសំរាប់ឲ្យចាំផ្ទះ ។

ចំណែកនាងទាំងពីរជាម្ចាស់ តែងថ្ពេចអម្បោះជានិច្ចតាំងពីព្រលឹមដល់ព្រលប់ ។ ការដែលនាងធ្វើនេះ មានសភាពដ៏ល្មមគ្រប់គ្រាន់ដល់ការស្លៀកពាក់ខ្លួននាងនិងមនុស្សក្នុងផ្ទះ តែទាស់គ្មានវត្ថុដទៃដ៏ប្លែកពីបរទេស ។ នៅផ្ទះនាងដើរតែជើងទទេ ហើយពាក់ស្បែកជើងតែថ្ងៃអាទិត្យ ដែលទៅវិហារសូត្រធម៌ ។ ស្ត្រីទាំងពីរមិនដែលទៅផ្សារទេ បើផ្សារតែនៅជិតជាងវិហារ ព្រោះនាងខ្លាចគេមើលងាយ ដោយសារខ្លួនស្លៀកពាក់សំពត់អាវមិនល្អដូចគេ ។ ប៉ុន្តែបើនិយាយឲ្យដាច់ស្រេចទៅ ការសុខទុក្ខមិននៅតែលើអ្នកស្រុកឡើយ ។ នាងម៉ារតឺតនិងឡាតួរ បើចេញដើរទៅទីក្រៅមានសេចក្ដីព្រួយបន្តិច តែបើចូលមកដល់ទីលំនៅរបស់ខ្លួនវិញ មានសេចក្ដីសប្បាយបរិបូណ៌ ។ អ្នកបំរើទាំងពីរ កាលណាបានឃើញនាងកំពុងដើរទៅឯផ្លូវបំពើមូស ជាកន្លែងដែលខ្លួនអាចក្រឡេកមើលឃើញ ក៏បបួលគ្នារត់ទៅដឹកដៃនាងឲ្យឡើងយ៉ាងស្រួលមិនឲ្យលំបាកឡើយ ។ នាងសំឡឹងមើលមុខបាវទាំងពីរ ឃើញថាមានចិត្តត្រេកអរណាស់ កាលបានឃើញនាង ។ នាងមានសេចក្ដីសុខគ្រប់យ៉ាង គឺរូបក៏ស្អាត ឯកធនបត្តក៏មាន វត្ថុគ្រប់បែបក៏មានប្រើប្រាស់ អ្នកបំរើទាំងពីរ ជាមនុស្សឧស្សាហ៍ ហើយស្រឡាញ់នាងអស់ពីពោះ ។

ស្ត្រីទាំងពីរ ដោយអំណាចសេចក្ដីត្រូវការចិញ្ចឹមជីវិតស្មើគ្នា ក៏កើតសោយទុក្ខវេទនាដូចគ្នា យកគ្នាធ្វើជាមិត្តភក្ដិ រាប់អានគ្នាដូចបងប្អូន

បង្កើត មានសេចក្តីប្រាថ្នាតែមួយ មានប្រយោជន៍តែមួយ មានពេលអាហារតែមួយ ៗ តែអ្វីទាំងប៉ុន្មានរបស់នាង នៅជាមួយគ្នាទាំងអស់ ៗ ម្យ៉ាងទៀត ប្រសិនបើភ្លើងគឺកាមពីជាន់មុន ដែលខ្លាំងជាងភ្លើងគឺការរាប់អាន លោតែត្រឡប់កើតឡើងវិញម្តងៗ គង់មានសាសនាយ៉ាងបរិសុទ្ធថែមទាំងមានទំនៀមទំលាប់យ៉ាងប្រពៃជួយផង អាចតម្រង់នាងឲ្យត្រង់ផ្លូវដើម្បីទៅកាន់លោកខាងមុខ ដូចជាអណ្តាតប្រទីបដែលដាច់ផុតពីប្រឆេះ ហើយស្ទុះឡើងទៅលើអាកាស កាលណាគ្មានប្រេងនៅលើផែនដី ៗ

កាលណាបានឃើញកុមារទាំងពីរ ដែលជាផលកើតមកអំពីកាមរាគប្រកបដោយសេចក្តីទុក្ខដូចគ្នា ចិត្តស្នេហាកាន់គ្នាទៅវិញទៅមក នៃនាងកើតឡើងជាទ្វេគុណ ៗ នាងចូលចិត្តឲ្យកូនដេកក្នុងអង្រឹងជាមួយគ្នា ៗ នាងផ្លាស់ប្តូរទឹកដោះគ្នាជាញឹកញយ ៗ នាងឡាគួរមានវាចាថា: "នៃសំឡាញ់! យើងម្នាក់តោងគិតថាមានកូនពីរ ហើយកូនយើងវិញក៏ត្រូវគិតថាមានម្តាយពីរដែរ" ៗ ហេតុដូច្នេះ ក្មេងទាំងពីរកំព្រាឪពុកដូចគ្នា តែងមានចិត្តទន់កាន់គ្នាទៅវិញទៅមក រាប់អានគ្នាដូចបងប្អូនពោះមួយ ៗ តាំងពីថ្ងៃដែលស្ត្រីទាំងពីរប្តូរទឹកដោះគ្នា ប្រៀបដូចជាពន្លកឈើពីរ ស្ថិតនៅលើរុក្ខជាតិពីរ ហើយដុះក្បែរគ្នា មានពូជតែមួយដែលព្យុះទើបតែនឹងបំបាក់មែកអស់ទៅ វេលាពន្លកណាដាច់ចេញពីដើមរបស់ខ្លួន គេយកទៅបំបៅនឹងដើមជិតខាង ៗ (មានត)

## សំណៀកបំពាក់ខ្មែរ

# របស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

(តចប់)

---

ហេតុដូចម្តេច បានជាយើងស្លៀកសំពត់ចងក្បិន? តើសំពត់ចងក្បិននេះមានដើមកំណើតអំពីណាមក? តាមយើងឮចាស់ៗ ដំណាលមកយូរហើយថា សំពត់នេះយើងស្លៀកតាមសាសន៍ក្លិង្គ ៗ ត្រង់នេះយើងមិនមានបំណងនឹងអធិប្បាយអំពីពង្សាវតារប្រទេសកម្ពុជា នឹងដើមកំណើតខ្មែរយើងទេ គឺយើងគ្រាន់តែសូមរំលឹកយ៉ាងសង្ខេបអំពីពង្សាវតារខ្មែរយើងបន្តិចថា: កាលពីដើមប្រទេសកម្ពុជាជាសមុទ្រដែលគោកទឹកបន្តិចម្តងៗ កើតមានមនុស្សសម្បុរជ្រះចូលមកនៅ, តមកជ្វាព្រាហ្មណ៍ គឺជាតិក្លិង្គដែលបានមកនៅក្នុងស្រុកជ្វាជាយូរហើយ មកពីស្រុកជ្វាចូលមកលុកលុយមកសោយរាជសម្បត្តិបង្កាត់កូនចៅលាយគ្នា រួចមកមានក្លិង្គសម្បុរខ្មៅហៅថាសាសន៍កម្ពុជាចូលមកបង្កាត់កូនចៅ ជាមួយនឹងអ្នកស្រុកនេះទៀត. ដូច្នេះឃើញថាដើមកំណើតជាតិខ្មែរមកអំពីអ្នកស្រុកហ្វូណន ជ្វាព្រាហ្មណ៍នឹងជាតិក្លិង្គ (ឥណ្ឌា) ដែលយើងហៅថាខ្មែរដើមឬកម្ពុ ៗ សាសន៍ក្លិង្គខ្មែរដើម ឬជាតិកម្ពុនោះក្នុងសម័យឥឡូវឃើញច្រើនស្លៀកសំពត់រ័ណ្ឋសំឡុយ ឥតដេរជាយភ្ជាប់គ្នាទេ ហើយចាប់ចុងជាយនោះយកមកចុកនៅចង្កេះពីក្រោយ មានរបៀបបែបដូចជាយើងស្លៀកសំពត់

ចង្កៀនដែរ; ដូច្នេះខ្មែរយើងស្លៀកសំពត់ចង្កៀនមកអំពីតាមសាសន៍នេះទេតើដែលជាសាសន៍ដើមកំណើតរបស់ខ្មែរយើង ។ តាមចាស់ៗដំណាលរឿងព្រេង ដែលទាក់ទងនឹងសំពត់ចង្កៀនថា: ខ្មែរយើងស្លៀកសំពត់ចង្កៀនតាមសាសន៍ក្លិង្គ ។ ដូចម្តេចបានជាក្លិង្គស្លៀកសំពត់ចង្កៀន? យើងដឹងថាក្លិង្គកាន់សាសនាច្រើនបែបណាស់ តែសាសនាដែលធំជាងគេ គឺព្រហ្មញ្ញសាសនា, ស្តេចខ្មែរយើងដែលកសាងនគរវត្តក៏ឧទ្ទិសចំពោះព្រហ្មញ្ញសាសនាដែរ ។ កាលសម័យបុរាណខ្មែរយើងនិយមរាប់អានរឿងរាមកេរ្តិ៍ណាស់ ជារឿងរបស់ព្រះដែលគេគោរព, មើលចុះមានផ្ទាំងចំឡាក់រឿងរាមកេរ្តិ៍ នៅនឹងកំពែងប្រាសាទនគរវត្តជាគោលបារកផង ។ ពាក្យដែលយើងសរសេរតទៅនេះជាពាក្យដែលយើងឮចាស់ទុំគេដំណាលតៗគ្នាមកថា ហេតុដែលសាសន៍ក្លិង្គស្លៀកសំពត់ចង្កៀនពីព្រោះក្លិង្គគេគោរពចំពោះហនុមានដែលជាទេវបុត្ររបស់គេមួយ, ហនុមានជាសេនាឯករបស់ព្រះរាមាយណៈដែលយើងហៅថាព្រះរាម, ហនុមានបានធ្វើគុណបំណាច់ថ្វាយព្រះរាមជាច្រើនដូចយើងដឹងស្រាប់ក្នុងរឿងរាមកេរ្តិ៍ ។ ដូច្នេះដើម្បីនឹងរំលឹកគុណហនុមាននោះ គេត្រូវស្លៀកពាក់ស ពីព្រោះហនុមានមានសម្បុរស ហើយគេស្លៀកសំពត់ឲ្យមានកន្ទុយ ពីព្រោះហនុមានជាតិជាសត្វស្វាសមានកន្ទុយ ។ ខ្លះទៀតថាក្លិង្គទាំងនោះជាពលនៅក្រោមអធិបតីភាពហនុមាន ប៉ុនជា

គេតែងខ្លួនស្លៀកពាក់ស ហើយបណ្ដុះកន្ទុយយ៉ាងដូច្នោះ ៗ បើនិយាយសារុបទៅ ឃើញថាសំពត់ចង្កៀនដែលខ្មែរយើងស្លៀកនេះ គឺយកតាមសាសន៍កុង្គដែលជាសាសន៍ដើមកំណើតខ្មែរយើង ហើយដែលមានបំណងធ្វើតាមហនុមានដែលជាសត្វស្វាសមានឥទ្ធិឫទ្ធិដ៏ល្បីល្បាញ ដែលជាសេនាឯករបស់ព្រះរាម ៗ តែឥឡូវនេះមិនតែប្រុសទេដែលស្លៀកសំពត់ចង្កៀន ស្រីក៏ស្លៀកដែរ ៗ ក្នុងរជ្ជកាលព្រះករុណានរោត្តម (គ. ស. ១៨៣៥ ដល់ ១៩១៤) គេស្លៀកចង្កៀនស្ដួយចុះទៅក្រោមរួមកនៅត្រឹមពាក់កណ្ដាលកំភួនជើង, ដល់មកចុងរជ្ជកាលព្រះករុណាស៊ីសុវត្ថិ (គ. ស. ១៨៤០ ដល់ ១៩២៩) និងក្នុងរជ្ជកាលព្រះករុណាស៊ីសុវត្ថិមុនីវង្ស (គ. ស. ១៨៧៥ ដល់ ១៩៤១) គេចង្កៀនខ្លីបទៅក្រោមជង្គង់បន្តិច គេថាធ្វើតាមសៀម; ចំណែកឯសៀម និងខ្មែរជាប្រទេសនៅជិតគ្នា សៀមយកបែបសំពត់ចង្កៀនពីខ្មែរទៅស្លៀកៗ មិនត្រឹមតែប្រុសថែមទាំងស្រីផង, លុះខ្មែរយើងឃើញថា ស្រីស្លៀកល្អដែរ ក៏នាំគ្នាស្លៀកតាមសៀម ៗ អ្នកស្រុកបាត់ដំបង និងសៀមរាបដែលនៅជិតសៀម ធ្វើតាមសៀម ស្លៀកសំពត់ចង្កៀនខ្លីបនៅត្រឹមជង្គង់ គឺខ្លីបជាងខ្មែរដែលនៅក្នុងភូមិភាគឯទៀត ៗ ឥឡូវនេះគេមិនសូវស្លៀកសំពត់ចង្កៀនទេ, គេស្លៀកតែក្នុងបុណ្យធំៗ ម្ដងៗ ៗ

សំពត់សំឡុយនឹងស្បៃពាគា — តាមយើងស្មានមើលទៅ ថា សំពត់សំឡុយ នឹងស្បៃពាគាដែលស្ត្រីខ្មែរបុរាណស្លៀកពាក់នោះ ក៏មកអំពីសាសន៍ឥណ្ឌដែរ ។ ចូរយើងសង្កេតមើលស្ត្រីឥណ្ឌ តើស្លៀកពាក់ដូចម្ដេច? គេស្លៀកសំពត់សំឡុយ នឹងរុំសំពត់ដែលហៅថាសារី ឃើញមានរបៀបប្រហែលគ្នាដែរ តែឥណ្ឌគេរុំច្រើនជុំ នៅចុងបន្តិចគេព័ទ្ធមកលើស្មា ។ ចំណែកខ្មែរយើងមានពីរយ៉ាង មួយយ៉ាងហៅថាស្បៃ ព័ទ្ធតែមួយជុំខ្លួន ហើយទម្លាក់ទៅក្រោយវែងអន្ទាយជិតដល់កែង, មួយយ៉ាងទៀតហៅថាផួយ ព័ទ្ធច្រើនជុំហើយទម្លាក់ទៅក្រោយ ធ្លាក់ចុះវែងអន្ទាយដែរ តែខ្មែរយើងព័ទ្ធរុំស្បៃនឹងផួយតែមួយកំណាត់ខ្លួនខាងលើហើយពាក់ទៅលើស្មាឆ្វេងទម្លាក់ទៅក្រោយ ។ ចំណែកឯស្ត្រីឥណ្ឌរុំតាំងអំពីក្រោមទៅដល់លើពាក់លើស្មាឆ្វេងដែរ ហើយទម្លាក់ទៅក្រោយបន្តិចឃើញថាខុសគ្នាប៉ុណ្ណោះ ។ កាលពីព្រេងនាយ ខ្មែរយើងហើយនឹងឥណ្ឌ ទំនងជាស្លៀកពាក់ដូចគ្នា, តែដោយសារនៅឆ្ងាយពីគ្នា មួយក៏យកផ្លូវស្រួលផ្លូវកាត់បង្ខិតទៅលើបន្តិចម្ដងៗ កើតទៅជាស្បៃនឹងផួយទៅ ។ ឯឥណ្ឌនេះតែចុះក្រោមទៅៗ សល់តែជាយបន្តិច ព័ទ្ធពាក់ទៅលើស្មា, តែមើលចុះគោលនៅនឹងដដែល គឺសំពត់វែងព័ទ្ធរុំជុំខ្លួន ព័ទ្ធពាក់ទម្លាក់ពីលើស្មាឆ្វេងទៅក្រោយ ។ សំពត់សំឡុយស្ត្រីឥណ្ឌឥតដេរជាយទេ តែស្លៀកសំពត់វែងធំកន្លាញ់ស្លៀកត្រង់ថ្នក់ បីដូចជាគេដប លែងរំសាយទៅក្រោម

មួយដុំ, ចំណែកស្ត្រីខ្មែរយើងពីបុរាណស្លៀកសំពត់ឥតដេរជាយព្រលាំនឹងស្ត្រីឥណ្ឌដែរ ហើយវែងណាស់ មានប្រវែងប៉ុននឹងសំពត់ចងក្បិន គឺ ៣ ម.២០ គេស្លៀកកក្ដាញ់ដីបជាយទាំងសងខាង ឲ្យនៅតែមួយដុំចង្កេះ ទើបគេស្លៀកពាក់ជាយថ្នក់មួយចូលទៅក្នុង ទម្លាក់ជាយថ្នក់មួយមកក្រៅ មានសណ្ឋានរីកបីដូចជាផ្ចិតមួយនៅត្រង់ផ្ចិត ឯពីមុខពីក្រោមផ្ចិតទៅក្រោមដីបរំសាយ បីដូចជាសំពត់ស្ត្រីឥណ្ឌដែរ ៗ ដូច្នេះខាងសំពត់មិនឃើញខុសគ្នាប៉ុន្មានទេ តែមកក្នុងសម័យឥឡូវសំពត់សំឡុយដែលខ្មែរយើងស្លៀកសព្វថ្ងៃ មានសណ្ឋានប្លែកពីសំពត់ដែលយើងស្លៀកពីសម័យបុរាណ នឹងប្លែកពីស្ត្រីឥណ្ឌហើយដោយជាតិយើងជាជាតិចូលចិត្តស្វែងរកសេចក្ដីស្រួល សេចក្ដីរហ័ស. សំពត់ស្ត្រីខ្មែរសព្វថ្ងៃដេរភ្ជាប់ជាយគ្នា ទាំងសងខាង មានរាងដូចថង់ហើយមានប្រវែងប្រមាណតាំងពី ១ ម.៦០ ដល់ ១ ម.៩០ ប៉ុណ្ណោះ ៗ កាលពីដើមយើងស្លៀកមានថ្នក់. ឥឡូវថ្នក់នោះកាន់តែស្តួចស្តើងទៅហើយ, មានខ្លះស្លៀកពុំឥតធ្វើជាថ្នក់ផង ៗ សេចក្ដីកែប្រែនេះ មានតាំងអំពីចុងរជ្ជកាលព្រះករុណាមុនីវង្ស ដល់ព្រះករុណាជាអម្ចាស់ជីវិតយើងសព្វថ្ងៃ ដោយអារ្យធម៌ប៉ែកអឺរ៉ុបចូលមកដល់ប្រទេសយើងកាន់តែច្រើនឡើង ៗ

នៅក្នុងរជ្ជកាលព្រះករុណានរោត្តម, ព្រះករុណាស៊ីសុវត្ថិនឹងព្រះករុណាមុនីវង្ស ស្ត្រីខ្មែរអ្នកក្រុងច្រើនពាក់អាវសម្ទុះ ប្រុសខ្មែរក៏ពាក់

អាវសន្ទុះដៃ តែមានសណ្ឋានប្លែកអំពីអាវសន្ទុះស្ត្រីបន្តិច អាវសន្ទុះស្ត្រីមានជាយខ្លួនធ្លាក់ដល់ក្រោមចង្កេះបន្តិច កម្ពូលតូចធំហាប៉ុនកមនុស្ស ពុះមុខដាក់សន្ទុះរហូតដល់ចុងដង្ហើម ដែលស្នាដូចអាវចិន ទម្លាក់ធ្លាក់មកត្រឹមក្លយដៃ, អាវសន្ទុះបុរសដៃធ្លាក់រហូតមកដល់កដៃ, ចំណែកខ្លួនទឹងកដូចអាវស្ត្រីដែរ តែបុរសច្រើនពាក់អាវនោះដាក់ក្នុងសំពត់ចងក្បៀន, ចំណែកស្ត្រីទម្លាក់ចុងខ្លួនអាវនៅក្រៅសំពត់ ។ បុរសពាក់អាវសន្ទុះសឹងតែគ្រប់កន្លែង, ចំណែកស្ត្រីវិញច្រើនតែអ្នកក្រុងទេ ដែលពាក់អាវសន្ទុះហើយបង់ក្រមាសំយុង ។

នៅក្នុងរជ្ជកាលព្រះករុណានរោត្តម ស្ត្រីអ្នកក្រុងច្រើនស្លៀកសំពត់សំឡុយពានាក្រមាវែងដែលគេហៅតាមពាក្យសៀមថាផាហ៊ុំ ។

អាវបំពង់វែង — អាវនេះដេរជ្រុង ៣ សងខាងខ្លួន កម្ពូលតូចធំហាប៉ុនកមនុស្ស ពុះមុខធ្លាក់ចុះមកដល់ចុងដង្ហើម ដៃតូចស្អួចវែងធ្លាក់ចុះមកដល់កដៃ ខ្លួនវែងសាយទៅក្រោម យកពងវៀរស្អួចចង្កេះតាមជ្រុង ៣, អាវនេះឃើញតែស្ត្រីទេពាក់ៗ សឹងតែគ្រប់ទីកន្លែង, ឥឡូវឃើញតែស្រុកស្រែទេដែលនៅពាក់អាវនេះខ្លះ ។

តើអាវនេះកើតមានតាំងពីណាមក? ដោយយើងសង្កេតមើលទៅឃើញថាសាសន៍ចាមជ្វាពាក់អាវនេះដែរ, សាសន៍ថៃដែលនៅក្នុងប្រទេសយួន ហើយដែលមានភាសាស្រដៀងគ្នា នឹងសាសន៍សៀមខ្មែរ, ក៏ពាក់

អាវប្រហែលនេះដែរ ។ ចំណែកអាវនេះទំនងជាអាវរបស់ស្រ្តីខ្មែរអំពីបុរាណហើយមើលទៅ, ពីព្រោះក្នុងពិធីច្រត់ព្រះនង្គ័លករិយារបស់តាត្រសក់ផ្អែមឃើញពាក់អាវនេះដែរ, តាមន័យទាំងនេះយើងយល់ថាអាវបំពង់វែងនេះទំនងជាមកអំពីសាសន៍ជ្វាទេឬ? ពីព្រោះសាសន៍ខ្មែរយើងកើតមកអំពីសាសន៍ជ្វាព្រាហ្មណ៍ ដែលនៅក្នុងស្រុកជ្វា កាលមកពីស្រុកជ្វាប្រហែលជានាំអារ្យធម៌ជ្វាមកខ្លះមិនខាន ។ ស្រ្តីខ្មែរស្លៀកសំពត់ហូលពាក់អាវនេះនឹងបង់ក្រមា, ចំណែកស្រ្តីចាមជ្វាក៏ស្លៀកពាក់សណ្ឋាននេះដែរ ។

អាវហាតាខិប – កាលក្នុងរជ្ជកាលព្រះករុណានរោត្តម (គ.ស. ១៨៣៥ ដល់ ១៩១៤) មានស្រ្តីសៀមជាច្រើនចូលមកគាល់បំរើព្រះរាជា ។ ស្រ្តីអ្នកក្រុងជាន់នោះ ច្រើនស្លៀកសំពត់ចងក្បិនពាក់អាវហាតាខិប ធ្វើតាមស្រ្តីសៀម ក្រវាត់ក្រមាព័ណ៌នៅចង្កេះ នឹងស្ពាយឆៀង ។ អាវហាតាខិបនោះមានកត្រង់ ប៊ដូចជាអាវកុតប្រុស តែធ្វើអំពីសំពត់ក្រណាត់ទន់ នៅជុំវិញកគេជីបដេររំសាយ ទម្លាក់មកក្រោម ៣ ជាន់ ដៃតូចវែងធ្លាក់ដល់ត្រឹមកដៃ នៅចុងដៃគេជីបដេរទម្លាក់រំសាយក្រញូលមកលើចុងដៃ ២ ឬ - ៣ ជាន់ទៀត ខ្លួនអាវពាក់ល្មមរែកពង់ប៉ុនខ្លួន ធ្លាក់ចុះមកត្រឹមចង្កេះ ហើយមានជីបដាក់ជុំវិញចង្កេះ

ទៀត ៗ គេឃើញមានពាក់អាវនេះតែអ្នកនៅក្នុងវាំង អ្នកនៅក្រុងទេ, ឯអ្នកស្រុកក្រៅមិនឃើញពាក់ឡើយ ៗ

អាវម៉ាឡាយូ— អាវនេះស្ត្រីខ្មែរពីដើមគេពាក់គូទឹងសំពត់សំឡុយ បង់ក្រមា ដៃវែងធំ ភ្ជាក់វែងចុះមកត្រឹមពាក់កណ្តាលកំភួនដៃ កដូចកអាវសុទ្ធ ខ្លួនវែងភ្ជាក់សាបចុះមកដល់កំភួនជើង ដូចអាវបំពង់វែងដែរ តែថ្នេរបំហៀងខ្លួនតែមួយ, អាវនេះទើបតែនឹងបាត់ឃើញពាក់ប្រមាណជាង ១០ ឬ ១៥ ឆ្នាំនេះទេ ៗ

ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

# ជីវប្រវត្តិ

## ព្រះសុធម្មបញ្ញោ កែវ-ជួប ចៅអធិការ

វត្តកោះប្រាក់ ឃុំកោះទន្ទឹម ស្រុកកំពង់សៀម ខេត្តកំពង់ចាម

## ព្រះភិក្ខុ ម៉ី-សាន រៀបរៀង

---

ព្រះថេរព្រះនាមព្រះសុធម្មបញ្ញោ កែវ-ជួប អង្គនេះ ជាអ្នកប្រាជ្ញផ្លូវធម៌វិន័យខាងព្រះពុទ្ធសាសនា មានសេចក្ដីយល់ត្រូវល្អ មានកិត្តិយសសមគួរតាមសមត្ថភាពរបស់លោក ជាធម្មកថិកសំដែងធម៌បំភ្លឺដល់ជនានុជន ក្នុងនានានិគមឲ្យបានភ្លឺស្វាង ឲ្យលះបង់អំពើខុសអាក្រក់ បែរមុខឈមទៅរកសេចក្ដីត្រូវល្អ អស់កាលជាយូរឆ្នាំមកហើយ មានកិត្តិសព្ទពីរោះល្អរន្ទឺសុះសាយដរាបដល់មកសព្វថ្ងៃនេះ គួរសំដែងប្រវត្តិរបស់លោកជាលាយល័ក្ខណ៍អក្សរទុកជាទីរឭក ដូចតទៅនេះ ៖

លោកកើតក្នុងថ្ងៃសុក្រ ៧ កើតខែអាសាឍ ឆ្នាំជូតនព្វស័ក ព. ស. ២៤១៩ (គ. ស. ១៨៧៦) បិតានាមកែវ មាតានាមអៀង នៅភូមិកោះគល់ ឃុំកោះមិត្រ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

កាលលោកនៅជាកុមារ បានសិក្សាអក្សរនិងលេខពីបិតាបានចេះខ្លះ លុះដល់អាយុ ១៥ ឆ្នាំ ទៅនៅរៀនអក្សរសាស្ត្រក្នុងសំណាក់លោកគ្រូសូត្រផង់ វត្តកោះរកា ក្នុងឃុំកោះរកា ស្រុកខេត្តជាមួយគ្នា បំពេញការសិក្សាអក្សរនិងលេខថែមទៀត ដរាបដល់ចេះមើលចេះសរសេរបាន

ព្រមទាំងរៀនធម៌វិន័យបំរុងបួសអស់ ១ ឆ្នាំ ។ ដល់អាយុ ១៦ ឆ្នាំទើបបព្វជ្ជាជាសាមណេរ ។

លុះបព្វជ្ជាហើយ បានមើលគម្ពីរជាច្រើនគឺអភិធម្ម ៧ គម្ពីរ, អភិធម្ម៩បរិច្ឆេទ, ទសជាតក, បឋមសម្ពោធិ, បឋមត្រាស់ជាដើម លោកបួសបាន ២ វស្សា ដល់អាយុ ១៨ ឆ្នាំ ត្រឡប់សឹកទៅជាឧបាសក នៅគ្រប់គ្រងគេហស្ថាន បានរក្សានិច្ចសីលជាប់មិនដាច់ធ្វើកិច្ចការបំរើមាតាបិតា អស់កាល ៤ ឆ្នាំ ។ ដល់អាយុ ២២ ឆ្នាំ ក្នុងឆ្នាំចសំរឹទ្ធិស័ក នាថ្ងៃសុក្រ ៦ កើតខែអាសាឍ ព. ស. ២៤៦១ ចូលមកឧបសម្បទាជាភិក្ខុភាវៈ ក្នុងពទ្ធសីមាវត្តកោះគល់ ឃុំកោះមិត្រ ស្រុកខេត្រដដែលវិញ មានលោកគ្រូវុឌ្ឍិវង្សាស៊ុ ជាព្រះឧបជ្ឈាយ៍ លោកគ្រូអរិយឃោសាទី ជាកម្មវាចា លោកគ្រូទិព្វថេរ គង់ ជាអនុសាវនា បាននាមបញ្ញត្តិថា សុធម្មបញ្ញាត្តោ ។

លុះឧបសម្បទាហើយ វស្សាទី ១ បានរៀនធម៌កាណាភរៈនឹងបាតិមោក្ខបាលីចាំស្ទាត់ដល់ចប់, វស្សាទី ២ ទៅនៅវត្តកណ្ដាលកោះសូទិន រៀនសមណធម៌នឹងព្រះត្រៃបិដក បានប្រែមូលកច្ចាយនៈនឹងធម្មបទខ្លះ ក្នុងសំណាក់លោកគ្រូអរិយឃោសាទី ជាកម្មវាចាចារ្យ ។ វស្សាទី ៣-៤ ត្រឡប់មកនៅវត្តកោះប្រាក់ បានរៀនមូលកច្ចាយនៈពីលោកគ្រូចៅអធិការព្រះនាមធម្មគិរី កែ-យក់ រៀនធម្មបទពីលោកគ្រូអាចារ្យកែវ (កេទ

ជាឧបាសក ) បានពាក់កណ្តាលខាងដើម ។ វស្សាទី ៥ ទៅនៅរៀនក្នុងសំណាក់លោកគ្រូអាចារ្យសន ចៅអធិការវត្តកំផែង ខែត្របាត់ដំបង ទឹងលោកគ្រូអាចារ្យ ជួប ( ឧបាសក ) បានរៀនគម្ពីរធម្មបទទៅខាងចុងទៀតដរាបដល់ចប់ ហើយរៀនមូលកច្ចាយន ថែមទៀត បានចំឡងវិន័យបាតិមោក្ខ ទឹងខ្ចួកវិះយពីលោកគ្រូអាចារ្យសន យកមកចែកឲ្យភិក្ខុសាមណេររៀនសូត្រ, លោកគង់នៅជាសុខសប្បាយក្នុងវត្តកំផែងនោះ អស់រវាងពីរឆ្នាំ ។ ដល់វស្សាទី ៧ ក្នុងឆ្នាំរោងឆស័ក ព.ស. ២៤៤៧ កាលនេះលោកកំពុងតែមានព្យាយាមពេញព្រះទ័យទឹងការសិក្សានៅក្នុងទីនោះ . ក៏ស្រាប់តែមានឧបសគ្គមកស្ទាក់ដំណើរឲ្យរអាក់រអួល ដោយមានភិក្ខុជាមិត្តសព្រហ្មចារ្យដែលទៅពីស្រុកជាមួយគ្នាមានជម្ងឺ លោកក៏ជូនភិក្ខុនោះមកកាន់ស្រុកកំណើតបំណងថានឹងត្រឡប់ទៅសិក្សាឯបាត់ដំបងវិញ តែដល់លោកនិមន្តមកដល់ស្រុកហើយក៏គង់នៅវត្តកោះប្រាក់រហូតមកដល់សព្វថ្ងៃនេះ ដោយលោកមានព្រះទ័យប្រាថ្នាបង់គង់នៅជិតមាតាបិតាដែលមានជរាភាពបៀតបៀនផង ដោយពេលនោះវត្តកោះប្រាក់មានការសិក្សាព្រះត្រៃបិដកកាន់តែចំរើនម៉ាំមួនឡើងផង លោកក៏សិក្សាតទៅ គឺរៀនគម្ពីរធម្មបទថែមទៀត, មង្គលត្ថទីបនី, សារត្ថសង្គហ, អាទិកម្ម, វិន័យមហាវគ្គខ្លះ ក្នុងសំណាក់លោកគ្រូអាចារ្យកែវ ( ឧបាសក ) អស់ពីរឆ្នាំ ។

វស្សាទី ៩ ឆ្នាំមមីអដ្ឋស័ក ព. ស. ២៤៤៩ លោកមានវិជ្ជាល្មមនឹងបង្រៀនគេបាន, សម័យនោះ លោកគ្រូព្រះធម្មគិរី កែ យក់ ចៅអធិការជាអធិបតី បានចាត់និមន្តលោកឲ្យបង្រៀនធម៌វិន័យដល់ភិក្ខុសាមណេរ, លោកក៏មានព្រះទ័យសោមនស្សជួយលើកដំកើងព្រះពុទ្ធសាសនា ទទួលធ្វើជាគ្រូបង្រៀនធម៌វិន័យ បានបង្ហាត់ភិក្ខុសាមណេរឲ្យសូត្រធម៌ត្រឹមត្រូវតាមអក្ខរវិធីនឹងរៀនប្រែតួសីលអង្គសិក្ខាបទជាដើម ព្រមទាំងបង្រៀនលេខនព្វន្តដល់ពួកកុមារផង អស់ ៣ ឆ្នាំ ។ តពីនោះមក លោកបង្រៀនបាលីនៅទីកុដិរបស់លោក ។

វស្សាទី ១៦ កុងឆ្នាំឆ្លូវបញ្ចស័ក ព. ស. ២៤៥៦ បានទទួលនាទីជាគ្រូសូត្រ ហើយទទួលភារៈកិច្ចការក្នុងវត្តទាំងអស់ជំនួសព្រះតេជព្រះគុណព្រះធម្មគិរី កែ-យក់ ដែលមានជរាភាពបៀតបៀន ។ វស្សាទី ៤៩ កុងឆ្នាំចអដ្ឋស័ក ព. ស. ២៤៨៩ ព្រះតេជព្រះគុណព្រះធម្មគិរី កែ-យក់ ចៅអធិការសុគតទៅ លោកក៏បានទទួលនាទីជាចៅអធិការឡើង ។

លោកបានទទួលគ្រឿងឥស្សរិយយសពីរគឺ: មេដៃយ៍មាសអំពីព្រះករុណាម្ចាស់ជីវិតព្រះបាទសម្តេចព្រះស៊ីសុវត្ថិមុនីវង្ស ព្រះចៅក្រុងកម្ពុជា ដោយគុណសម្បត្តិផ្សេងៗ ( ១៣ សីហា ) ១. អស្សរិទ្ធិមនីសាពក័ណអំពីព្រះករុណាម្ចាស់ជីវិតព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជា ដោយគុណបំណាច់វិជ្ជាផ្សេងៗ ( ១ វិច្ឆិកា ១៩៤៩ ) ១ ។

# បុញ្ញកិរិយាវត្ថុ
## ដែលព្រះសុធម្មបញ្ញោ កែវ-ជួប បានសាង

លោកបានធ្វើបុញ្ញកិរិយាវត្ថុជាច្រើនគឺ បានជួយសាងចេតិយធំ ១ ជាទីបញ្ចុះព្រះសារីរិកធាតុ មានព្រះធម្មគិរី កែ-យក់ ជាប្រធាន, បានសាងកុដិ ១ សម្រាប់ភិក្ខុ-សាមណេរនៅអាស្រ័យ, បានកាត់ទីវត្តដែលបង្អៀតស្តុកស្តាញដោយព្រៃ លើកដីកលប់ថ្កុកឲ្យរាបស្មើទូលាយរលីង ស្អាត, បានជីកស្រះជាស្នាមក្ដោះព័ទ្ធជុំវិញជាកសិណរបស់វត្ត, បានសាងសាលាបាលីរង ១ ខ្នង, បានទំនុកបំរុងឲ្យមានអាចារ្យបង្រៀនដល់ភិក្ខុសាមណេរ, បានធ្វើបុណ្យឆ្លងសាលាបាលីរង, បានជួសជុលវិហារចាស់ឲ្យជាថ្មីមានសណ្ឋានប្លែកឡើង. បានជួសជុលរបងនឹងក្លោងទ្វារនៃចេតិយចាស់ឲ្យជាថ្មីឡើង, បានរចនាបល្ល័ង្កជាក្បាច់រំលេចពណ៌ដោយថ្នាំគំនូរ បានសាងបដិសណ្ឋារសាលា ១ សម្រាប់ទទួលភ្ញៀវធ្វើបុណ្យនឹងសន្និបាតជំនុំការ, បានធ្វើបុណ្យឈាបនកិច្ចព្រះធម្មគិរី កែ-យក់ ចៅអធិការនឹងបុណ្យឆ្លងវិហារ, ក្នុងបុណ្យនោះបានសាងព្រះពុទ្ធរូបពីរព្រះអង្គគឺមាស ១ ព្រះអង្គ ប្រាក់ ១ ព្រះអង្គ, បានសាងសាលារៀនពីរខ្នង ១ ខ្នងពីរថ្នាក់ ១ ខ្នងទៀត ៣ ថ្នាក់ជូនរាជការ, បានទំនុកបំរុងឲ្យមានគ្រូបង្រៀនអក្សរសាស្ត្រខ្មែរ បាំងដល់ពួកកុមារីតាមផ្លូវរាជការ, បានជួយសង្គ្រោះដឹកនាំវិហារសាលាកុដិវត្តក្បាលកោះប្រាក់ ដែលមានភ័យអំពីច្រាំងបាក់

យកមកសង់ក្នុងវត្តរបស់លោក (១៩២៧). បានជួសជុលសាលាសម្រាប់ធ្វើបុណ្យដែលចាស់ទ្រេតទ្រោតឲ្យរឹងប៉ឹងមាំមួនឡើងវិញ, បានណែនាំមាតាបិតាឲ្យតាំងនៅក្នុងសីលធម៌; បានចាត់ភិក្ខុសាមណេរឲ្យទៅឲ្យសីលដល់មាតាបិតានឹងក្រុមញាតិរបស់លោកជានិច្ចរាល់ថ្ងៃសីល, បានព្យាបាលរក្សាជម្ងឺមាតាបិតា លុះដល់គាត់អនិច្ចកម្មទៅ បានធ្វើបុណ្យឈាបនកិច្ចជាទីបំផុត, ក្នុងបុណ្យនោះបានសាងព្រះពុទ្ធរូប ២ អង្គ គឺមាស ១ ព្រះអង្គ ប្រាក់មួយព្រះអង្គ, បានធ្វើបុណ្យឈាបនកិច្ចលោកគ្រូអាចារ្យកែវ ធម្មាចារ្យរបស់លោក, បានសាងអណ្តូងទឹក ១. បានធ្វើបុណ្យឈាបនកិច្ចលោកគ្រូអាចារ្យ ជួន-ជា ជាការកត្ថេររបស់លោក, បានទំនុកបំរុងបុណ្យឈាបនកិច្ចលោកគ្រូលន់ចៅអធិការវត្តក្បាលកោះប្រាក់, បានថែគម្ពីរនឹងបុរាណវត្ថុផ្សេងៗគឺៈគម្ពីរមនោរថបូរណីអដ្ឋកថា អង្គុត្តរនិកាយនិបាត ១៥ ខ្សែ, អនុដីកាវិភង្គ ១០ ខ្សែ, វិនយក្ខន្ធកនិទ្ទេស ១១ ខ្សែ, ឯកវិមតិវិនោទនីដីកាព្រះអាទិកម្ម ១៥ ខ្សែ, ការណកេះ ៩ ខ្សែ ជាដើម, ឯបុរាណវត្ថុ មានទូ, ត្រែទេសនា ស្នែងរមាំងក្ងស់, ខ្សែរុំគម្ពីរលាយល័ក្ខណ៍អក្សរជាដើម; ទៅដំកល់ទុកក្នុងព្រះរាជបណ្ណាល័យកម្ពុជា នៅក្រុងភ្នំពេញ ក្នុងឆ្នាំថោះនព្វស័ក គ. ស ១៩២៧ ដោយការរួបរួមជាមួយនឹងព្រះធម្មគិរី កែ-យក់ ជាចៅអធិការ, បានសាងគម្ពីរជាច្រើនគឺៈ ធម្មបទ ១ បច់; មង្គលត្ថទីបនី ១ បច់, សារត្ថសង្គហ ១ បច់, មូលកច្ចាយនៈ ១

ចប់ គាណាវារៈ ១ ចប់, អាទិកម្ម ១ ចប់; វិសុទ្ធិមគ្គ ១ ចប់, ព្រះត្រៃបិដកបាលីសម្រាយអក្សរខ្មែរ ១ ចប់, ។ ល ។ សៀវភៅឯទៀតគឺ វចនានុក្រមខ្មែរ វុត្តោទ័យ គិហិបដិបត្តិ, កច្ចាយនរូបត្ថមកៈ, រតនបរិត្ត (ពន្លឺកែវ), វិជ្ជាចរណកថា, បព្ពជ្ជាខន្ធកសង្ខេប បាតិមោក្ខសង្ខេប, ។ ល ។ បានសាងចេតិយ ១ បញ្ចុះអដ្ឋិធាតុ ព្រះធម្មគីរី កែ-យក់ ជាអធិការ និងមាតាបិតារបស់លោក, បានចូលពុទ្ធិកសមាគមកម្មជាអដ្ឋ ជាកម្មិកសមាជិកប៉ុមហាទាយក, បានបង្កើតឲ្យមានធម្មទេសនាចាត់ធម្មកថិកឲ្យសំដែងធម៌ក្នុងវិហារនិងសាលាបាលីរៀងរាល់ថ្ងៃសីល, បានចូលសមាគមគិលានសង្គ្រោះ សម្រាប់ព្រះសង្ឃខ្មែរ ចុះឈ្មោះសទិទ្ធសមាជិក ។ ល ។

## ការប្រតិបត្តិ
## របស់ព្រះសុធម្មត្ថេរ កែវ-ជួប

ព្រះមហាថេរអង្គនេះ លោកមានព្រះទ័យធូន់ធ្ង សភាពទន់ភ្លន់បរិបូណ៌ដោយសីលនិងកល្យាណធម៌ មានចរិយាសណ្ដាប់ធ្នាប់សមរម្យគួរជាទីរីករាយជ្រះថ្លានៃពុទ្ធសាសនិកជនទាំងឡាយ, ប្រកបដោយកតញ្ញូតាធម៌និងវុឌ្ឍាបច្ចាយនធម៌ លោកជាអ្នកតាំងនៅក្នុងសប្បុរសធម៌ព្រមទាំងស្គាល់ហេតុផលល្អអាក្រក់ ស្គាល់ថ្នាក់លំដាប់នៃការចេះដឹងជាដើមរបស់លោក ដឹងប្រមាណក្នុងការទទួលជាដើម និងពេលវេលា

ត្រូវប្រកបកិច្ចទាំងពួង ស្គាល់ប្រជុំជនទាំងបុគ្គលដែលគួរសេពគប់និងមិនគួរសេពគប់, ប្រកបដោយសង្គហវត្ថុទាំង ៤ ប្រការ ច្រើនទៅដោយសេចក្តីសង្គ្រោះ អាណិតអាសូរចំពោះអ្នកតូច ដោយការចែកឲ្យនូវបច្ច័យ ៤ មានចីវរជាដើម ដល់ភិក្ខុសាមណេរ និងបំណាយទេយ្យវត្ថុសាងសាលារៀនជាដើម តែងមានព្រះពុទ្ធដីកាប្រស្រ័យនឹងជនដែលចូលទៅរក ដោយពាក្យដ៏ពិរោះជាបិយវាចា ជាពាក្យគួរដល់កិច្ចការតាមផ្លូវច្បាប់ដ៏ពិតមិនលើសមិនខ្វះ មានព្យាយាមរឹងប៉ឹង ជ្រើសរើសធ្វើតែអំពើល្អប្រព្រឹត្តធ្វើកិច្ចជាប្រយោជន៍ដល់ពុទ្ធសាសនា ដល់ព្រះអគ្គលោកនិងជនដទៃ ៗ

គុណធម៌របស់លោកទាំងនេះ បានជាទិដ្ឋានុគតិ ជាគម្រាប់ដល់សាធុជនទាំងពួង ជនដែលបានប្រតិបត្តិតាម ក៏បានសេចក្តីសុខស្រួលដោយសារលោក ៗ ក្នុងពេលសន្និបាតម្តងៗ ឬពេលដែលជួបប្រសព្វនឹងអ្នកដែលចូលទៅរក ច្រើតែនាំយកពាក្យសុភាសិតមកថ្លែងជារឿយៗ មានសុភាសិតដូច្នេះជាដើមថា:

កុំស្មោកគ្រោកវាថោកការ កុំធីកស្រាវាដាច់ស័ល
កុំស៊ីច្រើនវាច្រើនខ្ជិល កុំកកិលវាថោកឫក ៗ
ការងារថោកថយព្រោះខ្ជិល ដាច់ស័លសត្យាព្រោះប្រមឹក
ស៊ីហួសប្រមាណច្រអូសស្ពឹក ថោកឫកព្រោះតែប្រកាន់កិល ៗ

# ឱវាទរបស់ព្រះសុធម្មបញ្ញោ កែវ ជួប

ភិក្ខុបាតិមោក្ខ អាចរាំងបាំងអបាយ
ភិក្ខុថ្មីទាំងឡាយ ត្រូវខ្វល់ខ្វាយរៀនប្រតិបត្តិ ។
ភិក្ខុតិរោកុំ ក្រៅជញ្ជាំងព្រះបញ្ញត្តិ
បួសហើយបែរជាកាត់ ចោលជញ្ជាំងគឺវិន័យ ។
ដូចសត្វពពោខ ទំមែកពោធិ៍ស៊ីផ្លែជ្រៃ
ឬថាដូចបក្ស លោតចុះចាកមែករុក្ខា ។
ស្លៀកស្បង់មិនកោរសក់ ធ្លុះកញ្ចក់ឆ្មេចនេត្រា
វិន័យបុសសាសនា មិនទីកនាសិក្សាសោះ ។

ថ្ងៃ ៣ ១៣ ៗ ៤ ឆ្នាំខាលទោស័ក

ព. ស. ២៤៩៣ គ. ស. ១៩៥១

អ្នករៀបរៀង ភិក្ខុ ម៉ី - សាន